## ផ្នែក គ

# បំណិនជីវិត
# ដែលអាចកសាង
# លទ្ធភាពស្តារឡើងវិញ
# របស់បុគ្គល



# មេរៀនទី១៣ ៖ ជំនាញក្នុងការនិយាយ(ជំនាញក្នុងការប្រាស្រ័យទាក់ទង) ១៣

## បំណងបំណង

អ្នកចូលរួមនឹងចេះបែងចែករបៀបប្រាស្រ័យទាក់ទងបែបហ្មត់ចត់ បែបក្រេវក្រោធ និងបែបទន់ភ្លន់ ហើយនឹងរៀនកសាងជំនាញទំនាក់ទំនងបែបហ្មត់ចត់ ដូច្នេះគេមិនបដិសេធន៍សិទ្ធិផ្ទាល់ខ្លួន របស់ពួកគេ។

## ពេលវេលា

៧៥ នាទី

## ការត្រៀម

កាត់ប្រយោគ សម្រាប់ទំនាក់ទំនងទៅជាមួយប្រយោគៗ ដាច់ដោយឡែកពីគ្នា និងដាក់ វាចូលទៅក្នុងថង់។ ជម្រើសមួយផ្សេងទៀត៖ កាត់ប្រយោគ ចេញពីគ្នា ហើយបិទវាម្តងមួយៗ ជាប់ទៅនឹងបាល់មួយ ដូច្នេះគេអាចយក វាម្តងមួយៗបាន។

## សម្ភារៈ

- ថតចម្លងមួយច្បាប់នៃ "IS ១៣ក ៖ ប្រយោគសម្រាប់ទំនាក់ទំនង"
- ស្កុតបិទ
- ថង់មួយ
- ស្លរគ្រាប់សម្រាប់អ្នកចូលរួមគ្រប់រូប
- ក្រដាសផ្ទាំងធំ

## សេចក្តីផ្តើម

**ការស្វាគមន៍**

ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះ។ ហុចតគ្នានូវបញ្ជីឈ្មោះចុះហត្ថលេខាវត្តមាន។

**សកម្មភាពមុនចាប់ផ្តើម**

ឲ្យអ្នកសម្របសម្រួលជាយុវជនជ្រើសរើសសកម្មភាពចាប់ផ្តើមមុននៅក្នុងតារាង។

**ការរំឭកមេរៀន**

មិនមាន។

### ការណែនាំអំពីបំណិនជីវិត

ពន្យល់ថា ប៉ុន្មានមេរៀនបន្ទាប់ទៀត គឺនិយាយអំពីបំណិនជីវិតដែលអាចជួយការពារមនុស្សពីការជួញដូរមនុស្សបាន។

## ការពិភាក្សា

ពន្យល់អ្នកចូលរួមថា មេរៀននេះគឺជាការជជែកពិភាក្សាគ្នា

ពន្យល់ថា នៅក្នុងប្រទេសនេះមនុស្សធំគិតទុកថាយុវវ័យនឹងនិយាយក្នុងទិដ្ឋភាពជាក់លាក់មួយ៖

- តើគ្រូរបស់អ្នកសួរសំណួរអ្នកអំពីមតិយោបល់របស់អ្នកដែរ ឬទេ? (មិនមែនគ្រាន់តែជាសំណួរសួររកទិន្នន័យ ឬចម្លើយត្រឹមត្រូវប៉ុណ្ណោះទេ ប៉ុន្តែគឺសួរអំពីយោបល់របស់អ្នក?)
- តើឪពុកម្តាយ របស់អ្នកសុំអ្នកឲ្យបញ្ចេញយោបល់អំពីបញ្ហាដែលប៉ះពាល់ដល់គ្រួសារដែរឬទេ?

- តើមាននរណាអាចឲ្យឧទាហរណ៍មួយដល់ខ្ញុំអំពីថា តើមនុស្សធំរំពឹងទុកថា ក្មេងម្នាក់នឹងនិយាយទៅកាន់គេយ៉ាងដូចម្តេចបានដែរ ឬទេ?
- តើអ្នកនិយាយអំពីអ្វីជាមួយនឹងឪពុកម្តាយរបស់អ្នក?
- តើអ្នកនិយាយអំពីអ្វីជាមួយនឹងឪពុកម្តាយរបស់អ្នក? តើមានរឿងដែលអ្នកមិនអាចជជែកជាមួយនឹងមនុស្សធំ ប៉ុន្តែអាចជជែកជាមួយមិត្តរបស់អ្នកបានដែរ ឬទេ?
- តើមានប្រធានបទដែលអ្នកចង់ពិភាក្សាជាមួយឪពុកម្តាយរបស់អ្នក ប៉ុន្តែហាក់បីដូចជាមិនសូវគួរសមក្នុងការពិភាក្សាជាមួយមនុស្សធំដែរ ឬទេ? តើជាប្រធានបទអ្វីខ្លះ?

លើកទឹកចិត្តឲ្យអ្នកចូលរួមពិភាក្សាអំពីសំណួរខាងលើ និងពិនិត្យរកភាពខុសគ្នានៃមតិយោបល់។ នៅពេលពួកគេធ្វើរួចចូលពិនិត្យមើលថាតើក្រុមគេអាចប្រើប្រាស់ឧទាហរណ៍ ដើម្បីបង្កើតជាការអធិប្បាយអំពីថាតើយុវវ័យនៅក្នុងភូមិនេះត្រូវបានគេរំពឹងទុកថា នឹងធ្វើការប្រាស្រ័យទាក់ទងដោយរបៀបណា?

ពន្យល់ថា នៅក្នុង SNYC ពួកគេនឹងត្រូវហ្វឹកហាត់បញ្ចេញមតិ។ ការនិយាយស្តី មានន័យថា ការបញ្ចេញយោបល់ ការឆ្លើយសំណួរ និងកាជជជែកអំពីរឿងសំខាន់ៗ។ ក្នុងវប្បធម៌នេះមិនមែនសុទ្ធជារឿងធម្មតានោះទេសម្រាប់យុវវ័យក្នុងការនិយាយស្តី។ (ដោយសារប្រទេសផ្សេងៗគ្នានៅក្នុងតំបន់ នឹងមានឥរិយាបថខុសគ្នាចំពោះយុវវ័យក្នុងការនិយាយស្តីផងដែរ នេះគឺជា ឱកាសល្អសម្រាប់អ្នកសម្របសម្រួលក្នុងការពិភាក្សាអំពីការរំពឹងទុកនានារបស់យុវវ័យនៅក្នុងប្រទេសជាក់លាក់របស់ខ្លួន)។ ពន្យល់ថា ក្នុងយុគសម័យទំនើបនេះ វាមានសារៈសំខាន់ណាស់ក្នុងការសម្តែងមតិរបស់អ្នកដើម្បីការពារខ្លួនអ្នកពីការជួញដូរ និងគ្រោះថ្នាក់ផ្សេងៗទៀត ដើម្បីទទួលបានអ្វីដែលអ្នកចង់បានសម្រាប់ជីវិតរបស់អ្នក។

## ទម្រង់ផ្សេងៗនៃការទំនាក់ទំនង

គូសបន្ទាត់វែងមួយកាត់ក្រដាសផ្ទាំងធំ។ នៅចុងម្ខាងនៃបន្ទាត់ សរសេរពាក្យថាទំនាក់ទំនងបែបក្រេវក្រោធ នៅចំកណ្តាល សរសេរពាក្យថា ទំនាក់ទំនងបែបហ្មត់ចត់ ហើយនៅចុងម្ខាងទៀតនៃបន្ទាត់ សរសេរពាក្យថា ទំនាក់ទំនងបែបទន់ជ្រាយ ។

### ទំនាក់ទំនងបែបហ្មត់ចត់

សួរអ្នកចូលរួមថា តើគេគិតថា ទំនាក់ទំនងបែបហ្មត់ចត់ មានន័យយ៉ាងដូចម្តេច?
ទំនាក់ទំនងបែបហ្មត់ចត់ មានន័យថា បុគ្គលម្នាក់និយាយទៅកាន់បុគ្គលម្នាក់ទៀតដោយការគោរព ហើយស្របពេលជាមួយគ្នានេះ គឺមិនបដិសេធន៍សិទ្ធិរបស់បុគ្គលម្នាក់ទៀតនោះទេ។
ពន្យល់ថា ការទំនាក់ទំនងដោយភាពច្បាស់លាស់ មានន័យថា អ្នក ៖
សុំដោយការគួរសមឲ្យគេប្រព្រឹត្តមកលើដោយស្មើភាព។(ឧទាហរណ៍ថា ពន្យល់ដោយយកចិត្តទុកដាក់ថា ក្មេងស្រីក៏មានសិទ្ធិទទួលបានការអប់រំដូចក្មេងប្រុសដែរ)
និយាយត្រង់ៗ។ (ឧទាហរណ៍ថា ប្រសិនបើមានមនុស្សមិនធ្លាប់ស្គាល់ម្នាក់នៅលើរថយន្តក្រុងមានការងារឲ្យអ្នកធ្វើ អ្នកត្រូវឆ្លើយតបថា "ទេ ខ្ញុំមិនស្គាល់អ្នកទេ។ ខ្ញុំមិនអាចទទួលយកការងារពីអ្នកដែលមិនធ្លាប់ស្គាល់ទេ។")

និយាយបែបជាក់លាក់។(ឧទាហរណ៍ថាប្រសិនបើនិយោជកម្នាក់និយាយថាអ្នកនឹងទទួលបាន ប្រាក់ខែល្អនោះ អ្នកត្រូវសួរដោយគួរសមថា តើប្រាក់ខែនោះប៉ុន្មានដែរ នៅពេលបើក ហើយតើ ប្រាក់ខែនឹងបើកឲ្យដោយរបៀបណាដែរ)។

សំឡឹងមើលមុខមនុស្សដែលអ្នកនិយាយជាមួយ។ (ក្នុងវប្បធម៌មួយចំនួន វាមិនមែនជា ការគួរសមទេ ដែលអ្នកសំឡឹងចំភ្នែកមនុស្សធំ។ ប៉ុន្តែប្រសិនបើអ្នកអាយុធំល្មមអាចធ្វើដំណើរ និងធ្វើការបានដោយខ្លួនឯងហើយនោះ គឺអ្នកធំល្មមអាចមើលមុខមនុស្សដែលអ្នកកំពុងជជែក ជាមួយបានហើយ ។ ឧទហរណ៍ថាប្រសិនបើមានបុរសម្នាក់នៅចំណតរថយន្តក្រុងកំពុង ព្យាយាមជំរុញអ្នកឲ្យទៅជាមួយគេ ភាគច្រើនគឺបុរសនោះអាចនឹងចាកចេញពីអ្នកប្រសិនបើ សំឡឹងចំភ្នែកគាត់ពេលអ្នកនិយាយថា “ទេ” នោះ)។

មិនត្រូវទុកក្នុងចិត្ត(ឧទាហរណ៍ថាប្រសិនបើចៅហ្វាយរបស់អ្នកកំពុងព្យាយាមបង្ខំអ្នកឲ្យធ្វើការ លើសម៉ោងដោយខុសច្បាប់នោះ មិនត្រូវហៅឈ្មោះគាត់ដោយសម្តីគ្រគោះបោះបោកឡើយ គឺ ត្រូវពន្យល់គាត់ដោយសម្តីស្ងប់ថា ច្បាប់មិនតម្រូវឲ្យអ្នកធ្វើការលើសម៉ោងទេ)។

**ទំនាក់ទំនងបែបគ្រេវគ្រោធ**

ពន្យល់ថា ទំនាក់ទំនងបែបគ្រេវគ្រោធមានន័យថាបុគ្គលម្នាក់និយាយស្តីក្នុងរបៀបមួយដែលមិន មានការគោរព ហើយគ្រគោះបោះបោក ឬ ដោយកំហឹង។

ឧទាហរណ៍មួយនៃទំនាក់ទំនងបែបគ្រេវគ្រោធនេះគឺដូចជា ប្រសិនបើមាននរណាម្នាក់សុំខ្ចីប៊ិច អ្នកដោយគួសម្យមួយភ្នែត ហើយអ្នកស្រែកគំហកឲ្យគេវិញ។

**ទំនាក់ទំនងបែបទន់ជ្រាយ**

ពន្យល់ថា ទំនាក់ទំនងបែបទន់ជ្រាយ មានន័យថា បុគ្គម្នាក់និយាយដោយចេញពីចិត្ត ប៉ុន្តែក្នុង លក្ខណៈមួយដែលទន់ជ្រាយខ្លាំង ឬស្លូតបូតដែលបុគ្គលដែលបុគ្គលបដិសេធន៍សិទ្ធិរបស់គាត់។ នៅក្នុងទំនាក់ទំនងបែបទន់ជ្រាយ គឺបុគ្គលអ្នកសម្តែងយកចិត្តទុកដាក់លើសិទ្ធិអ្នកដទៃច្រើនជាង សិទ្ធិ ឬតម្រូវការរបស់ខ្លួន។

ឧទាហរណ៍នៃទំនាក់ទំនងបែបទន់ខ្សោយគឺថា ប្រសិនបើបុគ្គលម្នាក់នៅក្នុងថ្នាក់របស់អ្នកសុំ ចម្លងលំហាត់កកិច្ចការផ្ទះរបស់អ្នក ហើយអ្នកនិយាយថា យល់ព្រម បើទោះបីជាជាក់ស្តែងអ្នក មិនចង់ឲ្យគេចម្លងក៏ដោយ។

## ល្បែងអំពីប្រយោគសម្រាប់ការទំនាក់ទំនង

ឲ្យក្រុមងទះដៃ។ ពេលគេកំពុងទះដៃ ចូរហុច ថង់ដាក់ប្រយោគតៗគ្នាសម្រាប់ការទំនាក់ ទំនង។ ពន្យល់ថា នៅពេលដែលអ្នកលើកដៃឡើង ក្រុមត្រូវឈប់ទះដៃ ហើយនរណាដែល កំពុងកាន់ថងក្នុងពេលនោះ ត្រូវតែបិទភ្នែក ហើយលូកយកប្រយោគសម្រាប់ការទំនាក់ទំនង ទំនងមួយចេញក្រៅថង់ និងអានឲ្យឮៗ។ អ្នកដែលកាន់ប្រយោគសម្រាប់ទំនាក់ទំនងនោះ ត្រូវតែសម្រេចចិត្តថា ប្រយោគនោះ បរិយាយអំពីទំនាក់ទំនងបែបទន់ជ្រាយ បែបហ្មត់ចត់ ឬ ទំនាក់ទំនងបែបគ្រេវគ្រោធ។

ជម្រើសផ្សេងទៀត៖ ប្រើបាល់មួយដែលមានបិទប្រយោគទំនាក់ទំនងពីលើ។ បោះបាល់ទៅមក ក្នុងថ្នាក់រៀនតាមចង្វាក់ភ្លេង។ នៅពេលដែលចង្វាក់ភ្លេងឈប់ អ្នកដែលកំពុងកាន់បាល់ ត្រូវបក

ប្រយោគ មួយដែលបិទជាប់បាល់នោះចេញ ហើយអានឲ្យឮៗ។ (អ្នកសម្របសម្រួលអាចសម្រេច ជ្រើសយកវិធីសាស្ត្រមួយណាក៏បានតាមចិត្តចង់)។

បន្ទាប់ពីបានអានប្រយោគមួយហើយ អ្នកចូលរួមត្រូវបិទប្រយោគនោះនៅកន្លែងដែលគេគិតថា ជាកន្លែងរបស់វានៅលើបន្ទាត់នៃក្រដាស់ផ្ទាំងធំ។ (ឧទាហរណ៍ថា ប្រយោគដែល គ្រោះថ្នាក់ខ្លាំង ត្រូវបិទនៅចុងបន្ទាត់ខាងស្តាំ ចំណែកឯប្រយោគដែលគ្រោះថ្នាក់ល្មម ត្រូវបិទនៅចន្លោះ ចំណុចហ្មត់ចត់ និងគ្រោះថ្នាក់)។

## ល្បែងស្ករគ្រាប់

បែងចែកសិស្សជាពីរក្រុម។ ចែកស្ករគ្រាប់ឲ្យអ្នកចូលរួមម្នាក់មួយគ្រាប់ ហើយប្រាប់គេកុំឲ្យញ៉ាំរង់ចាំទាល់តែចប់ម៉ោងសិន។ ឲ្យអ្នកចូលរួមមួយក្រុមចេញទៅក្រៅថ្នាក់ ហើយប្រាប់គេឲ្យឈប់គិតពីការណែនាំពីដំបូងៗ ហើយឲ្យគេត្រឡប់មកបន្ទប់វិញ ហើយបន្ទាប់មកញ៉ាំស្ករគ្រាប់ភ្លាមៗ។ តមកទៀត ទៅកាន់ក្រុមមួយទៀត ហើយព្យាយាមអូសទាញពួកគេឲ្យញ៉ាំស្ករគ្រាប់ភ្លាមៗ។

បន្ទាននាទីក្រោយមក ពន្យល់ទៅកាន់ក្រុមទាំងមូលថា អ្វីដែរបានកើតឡើងអម្បាញ់មិញគឺជាការគ្រោងទុក។ សុំអាធ្យាស្រ័យចំពោះក្រុមអ្នកចូលរួមផងដោយសារប្រើល្បិចបញ្ឆោតពាក់កណ្តាលក្រុម។

ពន្យល់ថាសកម្មភាពនេះត្រូវបានធ្វើដោយសារតែសម្ពាធពីមិត្តភក្តិ។ សម្ពាធពីមិត្តភក្តិកើតមាននៅពេលដែលមនុស្សធ្វើអ្វីៗដោយសារតែមនុស្សផ្សេងទៀតដែលមានវ័យស្រករគ្នាបានធ្វើរឿងនោះរួចហើយ ហើយគេចង់ធ្វើឲ្យត្រូវតាមនោះដែរ។

ពិភាក្សាសំណួរខាងក្រោមជាមួយនឹងក្រុម ៖

- អ្នកត្រូវបានគេប្រាប់មិនឲ្យញ៉ាំស្ករគ្រាប់ទេ។ តើអ្នកមានអារម្មណ៍បែបណា នៅពេលដែលយុវវ័យ ផ្សេងទៀតព្យាយាមបញ្ចុះបញ្ចូលអ្នកឲ្យញ៉ាំដែរនោះ?
- តើមាននរណាម្នាក់មានអារម្មណ៍ឃ្លានខ្លាំងមួយរំពេចដែរ ឬទេ?
- តើមានអារម្មណ៍ខឹង ឬយល់ច្រឡំ?
- តើអ្នកមានអារម្មណ៍ថា ត្រូវបានអូសទាញដែរ ឬទេ?
- តើមាននរណាម្នាក់ គិតពីពេលវេលា នៅក្នុងជីវិតពិតដែរ ឬទេនៅពេលដែលអ្នកមាន អារម្មណ៍ថាត្រូវបានរងសម្ពាធពីអ្នកដទៃឲ្យធ្វើអ្វីដែលអ្នកមិនចង់ធ្វើនោះ?

អានសេណារីយ៉ូខាងក្រោមឲ្យក្រុមស្តាប់ ៖

ស គឺកំពុងបរិភោគមីនៅតូបតាមផ្លូវមួយក្នុងរាជធានី។ មានបុរសម្នាក់បានមកអង្គុយក្បែរនាង ហើយបានចាប់ផ្តើមជជែកជាមួយនាង។ ស បានប្រើពាក្យសម្តីបែបសមគួរចំពោះមនុស្សចាស់ ហើយនាងក៏ឆ្លើយសំណួររបស់គាត់។ នាងដឹងទេថា មិនមែនចេះតែមានសុវត្ថិភាពនោះទេក្នុងការនិយាយជាមួយនឹងមនុស្សដែលមិនធ្លាប់ស្គាល់នោះ។ បុរសនោះ ពិតជាអ្នកជួញដូរមនុស្ស ហើយគេបានសួរទៅនាងថា ៖

- តើអ្នកមានការងារធ្វើនៅទីនេះដែរ ឬទេ?
- តើអ្នកមកដល់ទីនេះយូរប៉ុណ្ណាហើយ?
- តើគ្រួសាររបស់អ្នកមានញាតិមិត្តនៅទីក្រុងដែរ ឬទេ?

- តើអ្នកចង់ឲ្យខ្ញុំជួយរកការងារឲ្យធ្វើមួយដែលពិតជាទទួលបានកម្រៃល្អដែរ ឬទេ?
- តើខ្ញុំអាចមើលឯកសារធ្វើដំណើររបស់អ្នកបានដែរ ឬទេ?

ពេលនេះឲ្យអ្នកចូលរួមពិភាក្សាអំពីសំណួរទាំងនេះ។ ទុកឲ្យការពិភាក្សាបន្តដំណើរការតាមតម្រូវការ៖

- តើចម្លើយបែបមុឺងម៉ាត់អ្វីខ្លះដែល ស គួរឆ្លើយទៅកាន់បុរសនោះដើម្បីឲ្យគេចាកចេញពីនាង?
- តើចម្លើយណាខ្លះដែលត្រូវល្អជាងគេបំផុត?
- តើវាជាការលំបាកដែរ ឬទេក្នុងការតវ៉ាទៅនឹងសម្ពាធបែបនេះ ? ហេតុអ្វី?
- តើមួយណាអាក្រក់ជាងចំពោះ ៖ ត្រូវឆ្លើយគ្រគោះបោះបោកទៅកាន់មនុស្សមិនស្គាល់គ្នា ឬត្រូវឲ្យគេជូញដូរ?
- តើអ្នកគិតថាមនុស្សដែលទើបស្គាល់គ្នាថ្មីៗនឹងអាចសួរអ្នកច្រើនសំណួរមួយរំពេចក្រោយពីបានជួបជាមួយអ្នកដែរ ឬទេ?

មិនមានកំណត់ហេតុពីមេរៀន ឬការសម្តែងរឿងនៅចុងបញ្ចប់នៃម៉ោងសិក្សានេះទេ?

**សង្ខេបមេរៀន**

- នៅក្នុងវប្បធម៌របស់យើង អ្នកមិនត្រូវបានរំពឹងទុកឲ្យចែករំលែកមតិយោបល់ ឬទស្សនៈរបស់ខ្លួន ជាមួយនឹងមនុស្សធំទេ។
- នៅក្នុងសម័យកាលទំនើបនេះ យើងត្រូវតែអាចនិយាយស្តីជាមួយមនុស្សធំ ដើម្បីការពារខ្លួនយើង។ យើងអាចប្រើប្រាស់ការទំនាក់ទំនងបែបមុឺងម៉ាត់ ដើម្បីធ្វើការងារនេះ។
- ការទំនាក់ទំនងបែបហ្មត់ចត់ មានន័យថា បុគ្គលម្នាក់និយាយស្តីក្នុងវិធីមួយដែលប្រព្រឹត្តលើអ្នកដទៃដោយការគោរព ហើយស្របពេលជាមួយគ្នានេះដែរ គឺគេមិនបដិសេធន៍សិទ្ធិរបស់ខ្លួនទេ។

## ការបិទបញ្ចប់

ប្រាប់ឲ្យយុវជនសរសេរឬសួរសំណួរ និង/ឬ ផ្តល់ជាព័ត៌មានត្រឡប់ និងប្រគល់ឲ្យទៅអ្នកសម្របសម្រួលដោយមិនបាច់បញ្ចេញឈ្មោះ។

អរគុណដល់អ្នកចូលរួមទាំងអស់គ្នាដែលបានករៀន។ បញ្ជាក់ឡើងវិញអំពីការប្រជុំក្លឹបពេលក្រោយ។ ប្រាប់ពួកគេថាពួកគេទទួលបានផ្កាយមួយទៀតសម្រាប់ការចូលរួមក្នុងម៉ោងសិក្សានេះ។ ឲ្យយុវជនប្រើប្រាស់ទំនាក់ទំនងបែបហ្មត់ចត់នៅក្នុងជីវិតរស់នៅរបស់គេនៅសប្តាហ៍ក្រោយ។

**អ្នកគួរឈប់រៀន ហើយទៅធ្វើការងារនៅក្នុងឡដុតឥដ្ឋមួយ។**
ជាការពិតណាស់ ខ្ញុំចូលចិត្តទៅសាលារៀន ហើយខ្ញុំចង់បន្តការសិក្សាទៀត។

**ទៅសាលារៀនគឺឆ្កួតហើយ អ្នកគួរតែធ្វើការងារដូចខ្ញុំដែរ ទៅ។**
អ្នកនិយាយត្រូវ។

**តើអ្នកអាចជួយយួរការបួបឲ្យខ្ញុំបន្តិចបានទេ?**
ទេ។ បំភ្លេចចោលទៅ។

**ខ្ញុំមិនអាចស្វែងរកការងារដែលល្អជាងការធ្វើការងារនៅក្នុងវាលស្រែនោះទេ។**
នោះដោយសារតែអ្នកឆ្កួត

**(ពីមនុស្សស្រីចំណាស់ម្នាក់ដែលអ្នកបានជួបនៅលើរថយន្តក្រុងមួយ)**
**អ្នកនឹងមិនមានសុវត្ថិភាពទេដែលនៅទីក្រុងតែឯងនោះ។ មកស្នាក់នៅជាមួយខ្ញុំមក។**
ខ្ញុំសូមទោស ប៉ុន្តែខ្ញុំមិនអាចទៅបានទេ។ ខ្ញុំទើបតែស្គាល់អ្នក។

**តើអ្នកចង់ថែមស្រាបៀរទៀតទេ?**
អត់ទេ។ អរគុណ ខ្ញុំអស់មួយហើយ។

**ចូលឡានមក ខ្ញុំអាចដឹកអ្នកទៅទីក្រុងបាន។**
អត់ទេ។ អរគុណ ខ្ញុំចង់ដើរវិញ។

**មកជាមួយខ្ញុំធ្វើចំណាកស្រុកទៅទីក្រុង ជីវិតនៅទីនេះយ៉ាប់ណាស់។**
ខ្ញុំសូមទោស ប៉ុន្តែខ្ញុំមិនអាចទេ។ ខ្ញុំត្រូវបញ្ចប់ការសិក្សារបស់ខ្ញុំសិន។

**(មកពីមិត្តភក្តិម្នាក់ដែលចូលចិត្តផឹកស៊ី) ៖**
**ប្រសិនបើអ្នកជាមិត្តភក្តិពិតប្រាកដ អ្នកត្រូវជិះម៉ូតូជាមួយខ្ញុំទៅផ្ទះ។**
ខ្ញុំជាមិត្តរបស់អ្នក ប៉ុន្តែខ្ញុំមិនមានអារម្មណ៍ស្រួលខ្លួនក្នុងការជិះម៉ូតូជាមួយអ្នកទេនៅពេលដែលអ្នកផឹកស្រាច្រើនបែបនេះ។

**តើអ្នកចង់ទៅដើរលេងនៅមាត់ទន្លេជាមួយខ្ញុំដែរទេ?**
អត់ទេ ។ អរគុណ ខ្ញុំចង់នៅទីនេះជាមួយមិត្តខ្ញុំទាំងអស់គ្នា។
**វាជាការខ្ជះខ្ជាយប្រាក់ដែលបញ្ជូនកូនអ្នកទៅសាលារៀន ដោយសារតែគាត់ជាក្មេងស្រី។**
ខ្ញុំសុំទោស។

**អ្នកមិនអាចជិះរថយន្តក្រុងទៅទីក្រុងដើម្បីរកការងារធ្វើដោយមិនមានផែនការបានទេ។**
ខ្ញុំមិនខ្វល់ទេ។ អ្នកតែងតែរិះគន់ពីនេះពីនោះមិនចប់។ ខ្ញុំធ្វើអ្វីដែលខ្ញុំចង់ធ្វើ។

**លេបថ្នាំនេះទៅ វានឹងធ្វើឲ្យអ្នកមានអារម្មណ៍ល្អនៅពេលអ្នកកំពុងធ្វើការ។**
អត់បញ្ហា។

**ក្មេងប្រុសម្នាក់ក្រីក្រណាស់។ ខ្ញុំគិតថា យើងមិនគួរលេងជាមួយគេបន្តទៀតទេ។**
អត់បញ្ហា។ ខ្ញុំនឹងមិននិយាយជាមួយគេទៀតទេ។

**អ្នកគួររកប្រាក់បានច្រើន ប្រសិនបើអ្នកទៅធ្វើការនៅទីក្រុង**
ខ្ញុំមិនសូវស្គាល់ទីក្រុងច្បាស់ទេ ហើយខ្ញុំខ្លាចថា វាមិនមានសុវត្ថិភាពសម្រាប់ខ្ញុំ។ ខ្ញុំចង់ទៅរៀនបន្តិចទៀតសិន ហើយចាំទៅទីក្រុងនៅពេលខ្ញុំធំជាងនេះ។

## ទិដ្ឋភាព

### ចំណុចបំណង
អ្នកចូលរួមនឹងរៀនអំពីជំនាញក្នុងការស្ដាប់ថ្មីមួយទៀត ដូច្នេះគេអាចជៀសវាងការយល់ច្រឡំនៅក្នុងដំណើររឿងស្ដីពីការជួញដូរមនុស្សសំខាន់ៗ

### ពេលវេលា
៧៥ នាទី

### ការត្រៀម

**សម្ភារៈ :**
- ថតចម្លងមួយច្បាប់នៃ **"ធន ១៥ក ៖ ជំនាញក្នុងការស្ដាប់បានល្អ"**

ក្រដាសផ្ទាំងធំ

### សេចក្ដីផ្ដើម

**ការស្វាគមន៍**

ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះ។ ហុចតគ្នានូវបញ្ជីឈ្មោះចុះហត្ថលេខាវត្តមាន។

**ល្បែងថាមពល**

ឲ្យអ្នកសម្របសម្រួលជាយុវជនជ្រើសរើសល្បែងថាមពលនៅក្នុងតារាង។

**ការរំឭកមេរៀន**

សួរថា តើមានអ្នកចូលរួមណាខ្លះ ដែលបានប្រើប្រាស់ទំនាក់ទំនងបែបម៉ឺងម៉ាត់ដៃរឬទេចាប់តាំងពីម៉ោងសិក្សាមុន ។

ប្រសិនបើគេបានធ្វើ តើគេមានអារម្មណ៍បែបណា?

តើអ្នកដទៃឆ្លើយតបយ៉ាងដូចម្ដេច?

## ជំនាញក្នុងការស្ដាប់បានល្អ

ពន្យល់ថា កាលពីមេរៀនមុនសិក្សាអំពីប្រភេទផ្សេងៗគ្នានៃការទំនាក់ទំនង រួមមានជំនាញទំនាក់ទំនងបែបហ្មត់ចត់ បែបទន់ខ្សោយ និងបែបក្រេវក្រោធ។ ជំនាញនិយាយបានល្អគឺជាផ្នែកដ៏សំខាន់នៃការទំនាក់ទំនង។ ប៉ុន្តែជំនាញក្នុងការស្ដាប់ក៏មានសារៈសំខាន់ដូចគ្នាដែរ។ បញ្ជាក់ឡើងវិញម្ដងទៀតដល់អ្នកចូលរួមថា គេមិនចាំបាច់ឆ្លើយតបវិញទេ ប្រសិនបើមានមនុស្សមិនធ្លាប់ស្គាល់ណាម្នាក់សួរគេនោះ។ គេអាចជ្រើសរើសជម្រើសនៅស្ងៀមបាន។ ប៉ុន្តែប្រសិនបើគេនិយាយទៅកាន់មនុស្សមិនធ្លាប់ស្គាល់នោះ ប្រាប់គេថា គួរប្រើជំនាញស្ដាប់ឲ្យបានល្អ។

**ជំនាញស្ដាប់មិនល្អ**

ពន្យល់ថា នៅពេលដែលមនុស្សស្ដាប់មិនបានល្អ គឺគេ ៖

- គិតអំពីអ្វីដែល គេចង់និយាយបន្ទាប់ទៀត ជំនួសឲ្យការស្ដាប់អំពីអ្វីដែលអ្នកដទៃកំពុងនិយាយ។

- មិនស្តាប់ព័ត៌មានលម្អិតសំខាន់ៗដែលគេបានឮ
- ចងចាំព័ត៌មានលម្អិតដែលមិនសំខាន់ៗ
- ប្រសិនបើយល់ច្រឡំសាច់រឿង ពួកគេធ្វើការគិតដោយខ្លួនឯងដើម្បីឲ្យសាច់រឿងនោះកាន់តែច្បាស់ទោះជាវាមិនមានក្នុងសាច់រឿងពិតក៏ដោយ។
- បែងចែកខ្លួនឯងទៅនិងរឿងផ្សេងៗទៀតក្នុងពេលតែមួយ។

**ជំនាញស្តាប់ដ៏ល្អ**

ពន្យល់ប្រាប់ថា នៅពេលដែលមនុស្សម្នាក់កំពុងស្តាប់បានយ៉ាងល្អនោះ គឺគេ ៖

- គិតអំពីអ្វីដែលអ្នកដទៃកំពុងនិយាយ។
- សួរសំណួរបញ្ជាក់អំពីអ្វីដែលគេមិនយល់។
- និយាយសារឡើងវិញអំពីអ្វីដែលគេទើបនិយាយរួច។
- គិតអំពីអ្វីដែលគេចង់ដឹងបន្ថែម និងសួរសំណួរទៅតាមនោះដែរ។

## ល្បែងអំពីជំនាញក្នុងការស្តាប់បានល្អ

ដាក់រូបភាព "IS ១៤ក ៖ ជំនាញក្នុងការស្តាប់ដ៏ល្អ" នៅត្រង់កន្លែងណាដែលក្រុមទាំងមូលអាចមើលឃើញ។ ឲ្យអ្នកចូលរួមស្វែងរកដៃគូមួយ។ ឲ្យគេដាក់វេនគ្នាដើម្បីនិយាយរឿងប្រាប់គ្នាម្តងម្នាក់។ ប្រសិនបើគេមិនដឹងនិយាយអំពីអ្វី ប្រាប់គេថា គេអាចប្រាប់អំពីរឿងមួយដែលគេបានឃើញតាមកញ្ចក់ទូរទស្សន៍ក៏បាន អ្វីដែលបានកើតឡើងនៅសាលារៀន ឬអ្វីដែលគេបានធ្វើកាលពីមេរៀនមុននៅក្នុងក្រុម។

ឲ្យអ្នកទីមួយនិយាយរឿងរបស់គេ អ្នកដទៃទៀតត្រូវអនុវត្តជំនាញក្នុងការស្តាប់បានល្អរបស់ខ្លួនដោយក្រឡេកមើលទៅរូបភាព "IS ១៤ក ៖ ជំនាញក្នុងការស្តាប់ល្អ" ដើម្បីឲ្យប្រាកដថាគេកំពុងសាកល្បងជំនាញទាំងអស់។

## ជំនាញក្នុងការស្តាប់ល្អអាចជួយការពារអ្នក

ពន្យល់ថា ជំនាញក្នុងការស្តាប់បានល្អអាចជួយឲ្យគេការពារខ្លួនគេពីស្ថានភាពគ្រោះថ្នាក់បាន។ អានរឿងខាងក្រោមឲ្យក្រុមស្តាប់។

> **ក** កំពុងធ្វើដំណើរតាមរថយន្តក្រុងមួយ ឆ្ពោះទៅកាន់ទីក្រុងដើម្បីរកការងារធ្វើ។ មនុស្សម្នាក់ដែលអង្គុយជាប់នាងចាប់ផ្តើមធ្វើការសន្ទនា។ ខាងក្រោមនេះ គឺជាអ្វីដែលមនុស្សម្នាក់នោះបាននិយាយ ៖ មនុស្សមិនធ្លាប់ស្គាល់ ៖ "អ្នកមើលទៅទំនងជាក្មេងស្រីម្នាក់ដ៏ល្អរួសរាយ និងចេះគោរព ឱនលំទោន។ ខ្ញុំមានបងប្អូនម្នាក់ដែលតែងតែរកកម្មករធ្វើការល្អ និងមានការគោរពបែបនេះ។ គាត់ជាម្ចាស់រោងចក្រកាត់ដេរមួយកន្លែងនៅខេត្តកំពត។"
>
> ក ៖ "ខ្ញុំមិនចេះដេរទេ។ ខ្ញុំមិនអាចធ្វើការនៅទីនោះបានទេ។"
>
> មនុស្សមិនធ្លាប់ស្គាល់ ៖ " អូ អ្នកមិនចាំបាច់ចេះជំនាញអ្វីទាំងអស់។ គេនឹងបង្រៀនអ្នក។ ហើយគេផ្តល់ប្រាក់ខែឲ្យខ្ពស់"
>
> ក ៖ "ខ្ញុំនឹងនិយាយជាមួយឪពុកម្តាយរបស់ខ្ញុំ ដើម្បីពិភាក្សាអំពីបញ្ហានេះសិន។"
>
> ស្ងៀមបន្តិច បន្ទាប់ពី១០នាទីមក ជនមិនធ្លាប់ស្គាល់នោះចាប់ផ្តើមនិយាយម្តងទៀត។

មនុស្សមិនធ្លាប់ស្គាល់ ៖ " វាគឺជាការងារដ៏ល្អណាស់ បានប្រាក់ច្រើនជាងការងារដែលអ្នកធ្វើនៅតាមរោងចក្រធម្មតា។ ប៉ុន្តែអ្នកត្រូវតែសម្រេចចិត្តក្នុងពេលនេះ។ គាត់ត្រូវការកម្មករជាបន្ទាន់ ពីព្រោះគាត់មានការបញ្ជាទិញដ៏ធំមួយ។ នេះហើយជាមូលហេតុដែលទទួលបានប្រាក់ខែខ្ពស់។ រថយន្តដឹកអ្នកដំណើរខ្នាតតូចមួយដែលនឹងនាំអ្នកទៅខេត្តកណ្តាល នឹងចាកចេញពីចំណតភ្លាមពេលរថយន្តក្រុងនេះទៅដល់នាងគ្មានពេលហៅទូរស័ព្ទទៅនរណាបានទេ។"

ក ប្រើជំនាញក្នុងការស្តាប់ដ៏ល្អ ដើម្បីគិតអំពីអ្វីដែលស្ត្រីម្នាក់នោះបាននិយាយ។

ឲ្យអ្នកចូលរួមពិចារណាថា តើផ្នែកមួយណានៃការផ្តល់ការងារដែលហាក់បីដូចជា មានភាពមិនស្រប។ ប្រសិនបើចំណុចខាងក្រោមទាំងនេះមិនបានលើកឡើងទេនោះ អ្នកត្រូវប្រាកដថា អ្នកបានលើកឡើង ៖

- ហេតុអ្វីបានជាស្ត្រីម្នាក់នោះនិយាយថា រោងចក្រនោះនៅក្នុងខេត្តកំពត ប៉ុន្តែបន្ទាប់មកទៀតគេនិយាយថា នាងនឹងត្រូវជិះរថយន្តដឹកអ្នកដំណើរខ្នាតតូចមួយទៅខេត្តកណ្តាលដែលជាកន្លែងនៅឆ្ងាយពីខេត្តកំពត។
- ហេតុអ្វីបានជាថៅកែត្រូវឲ្យប្រាក់ខែខ្ពស់ដល់អ្នកដែលមិនមានជំនាញ។
- តើថៅកែមានពេលពីណាដើម្បីបង្រៀននាង ប្រសិនបើគាត់មានការបញ្ជាទិញដ៏ធំដែលត្រូវបំពេញឲ្យគេជាបន្ទាន់។
- ហេតុអ្វីបានជានាងចាំបាច់ត្រូវធ្វើការសម្រេចចិត្តក្នុងរយៈពេលតែមួយថ្ងៃ។
- ជាមួយគ្នានេះដែរ នាងមិនធ្លាប់បានឮថាគ្មានមាននរណាត្រូវបានជ្រើសរើសឲ្យធ្វើការនៅក្នុងរោងចក្រកាត់ដេរ ដោយគ្មានការធ្វើតេស្តនោះទេ។

ពន្យល់ទៅអ្នកចូលរួមថា ក បានគិតអំពី អ្វីដែលស្ត្រីម្នាក់នោះកំពុងនិយាយ។ ក បានសួរទៅស្ត្រីនោះនូវ សំណួរបញ្ជាក់ច្បាស់លាស់ អំពីអ្វីដែលនាងមិនយល់។ ចម្លើយរបស់ស្ត្រីនោះកាន់តែខុសច្រើន។

ពន្យល់ថា មនុស្សតែងតែនិយាយខុសដោយខ្លួនឯងនៅពេលដែលគេកំពុងកុហក ពីព្រោះគេភ្លេចអ្វីដែលគេបាននិយាយពីមុន។ ក និយាយម្តងទៀត នូវអ្វីដែលស្ត្រីម្នាក់នោះ បាននិយាយពីខាងដើមនៅក្នុងការសន្ទនាដែលខុសពីអ្វីដែលនាងបាននិយាយបន្ទាប់មកទៀត។ ស្ត្រីនោះគឺជាអ្នកជួញដូរមនុស្ស ហើយគេកំពុងព្យាយាមបោកបញ្ឆោត ក។ ប៉ុន្តែសំណួរ របស់ ក ធ្វើឲ្យស្ត្រីនោះមានការភាន់ច្រឡំ ហើយគេដឹងច្បាស់ថា គេមិនអាចបញ្ឆោត ក បានទៀតទេ។ ស្ត្រីនោះចាកចេញពីរថយន្តក្រុងនៅចំណតបន្ទាប់។

## ការសម្តែងរឿង

ឲ្យអ្នកចូលរួមស្ម័គ្រចិត្តពីរនាក់ដើរតួសម្តែងជានិយោជកម្នាក់ និងជនចំណាកស្រុកម្នាក់កំពុងស្វែងរកការងារធ្វើ ដែលចរចាគ្នាអំពីការងារដែលអាចទៅរួច។ អ្នកចូលរួមផ្សេងទៀតអាចធ្វើជាអ្នកទស្សនា។

ពន្យល់ថា ដំបូងអ្នកស្ម័គ្រចិត្តសម្តែងរឿងដោយនិយោជកគួរប្រើរបៀបទំនាក់ទំនងបែបក្រេវ

ក្រោធ ហើយជនចំណាកស្រុកគួរប្រើទំនាក់ទំនងបែបអកម្ម និងជំនាញក្នុងការស្តាប់មិនល្អ។ ឲ្យអ្នកចូលរួម ស្ម័គ្រចិត្តពិភាក្សាគ្នាលម្អិតបន្ថែម អំពីអ្វីដែលគេបានគិតថាគួរកើតមានក្នុងការសម្តែងក្នុងរយៈពេល បី បួននាទី។ បន្ទាប់មកឲ្យគេសម្តែងតែម្តង។

នៅពេលដែលពួកគេបានបញ្ចប់ការសម្តែង សួរទៅក្រុមឲ្យបញ្ចេញមតិយោបល់អំពីរបៀបដែល ជំនាញក្នុងការទំនាក់ទំនងក្រេវក្រោធ ទំនាក់ទំនងបែបអកម្ម និងជំនាញក្នុងការស្តាប់មិនបានល្អ ធ្វើឲ្យស្ថានភាពកាន់តែអាក្រក់ទៅយ៉ាងដូចម្តេច។

បន្ទាប់មកទៀត ឲ្យអ្នកស្ម័គ្រចិត្តផ្សេងទៀត ធ្វើការសម្តែងឡើងវិញ ដោយប្រើជំនាញក្នុងការទំនាក់ទំនងបែបម៉ឺងម៉ាត់ ហើយជនចំណាកស្រុកប្រើប្រាស់ទំនាក់ទំនងបែបម៉ឺងម៉ាត់ និងជំនាញក្នុងការស្តាប់ដ៏ល្អ។

ជាថ្មីម្តងទៀត សួរទៅក្រុមឲ្យបញ្ចេញមតិយោបល់ អំពីរបៀបដែលជំនាញ ក្នុងការទំនាក់ទំនងបែបម៉ឺងម៉ាត់ និងជំនាញក្នុងការស្តាប់ដ៏ល្អ ធ្វើឲ្យស្ថានភាពកាន់តែល្អប្រសើរទៅបានយ៉ាងដូចម្តេច។

**សង្ខេបមេរៀន**

នៅពេលដែលមនុស្សកំពុងស្តាប់បានយ៉ាងល្អនោះ គឺគេ ៖

- គិតអំពីអ្វីដែលអ្នកដទៃកំពុងនិយាយ។
- សួរសំណួរបញ្ជាក់អំពីអ្វីដែលគេមិនយល់។
- និយាយសារឡើងវិញដោយពាក្យពេចន៍ខ្លួនឯងអំពីអ្វីដែលគេទើបនិយាយរួច។
- គិតអំពីអ្វីដែលគេចង់ដឹងបន្ថែម និងសួរសំណួរទៅតាមនោះដែរ។

ជំនាញក្នុងការស្តាប់បានល្អអាចជួយឲ្យសិស្សការពារខ្លួនគេពីស្ថានភាពគ្រោះថ្នាក់បានរួមទាំងក្នុងអំឡុងពេលកំពុងធ្វើចំណាកស្រុកផងដែរ។

## ការបិទបញ្ចប់

ប្រាប់ឲ្យអ្នកចូលរួមសរសេរ ឬសួរសំណួរ និង/ឬ ផ្តល់ជាព័ត៌មានត្រឡប់ ហើយប្រគល់ឲ្យទៅអ្នកសម្របសម្រួលដោយមិនបាច់បញ្ចេញឈ្មោះ។

អរគុណដល់អ្នកចូលរួមទាំងអស់គ្នាដែលបានមករៀន។ បញ្ជាក់ឡើងវិញអំពីការប្រជុំក្លិបពេលក្រោយ។ ប្រាប់ពួកគេថា ពួកគេទទួលបានផ្កាយមួយទៀតសម្រាប់ការចូលរួមក្នុងម៉ោងសិក្សានេះ។

ឲ្យអ្នកចូលរួមសង្កេតមើលប្រជាជននៅក្នុងសហគមន៍របស់គេ ហើយឆ្លើយសំណួរខាងក្រោម ៖

- តើអ្នកអាចព្យាយាម ប្រើការទំនាក់ទំនង បែបម៉ឺងម៉ាត់ នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់អ្នកបានដែរឬទេ?
- តើអ្នកអាចព្យាយាមប្រើជំនាញក្នុងការស្តាប់បានល្អនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់អ្នកបានដែរឬទេ?

អ្នកសម្របសម្រួលអាចសួរអ្នកចូលរួម ឲ្យសរសេរការណែនាំនេះលើក្រដាសហើយយកទៅផ្ទះដើម្បីរំឭក។





អ្នកដែលស្តាប់គេបានល្អគឺជាអ្នកដែល ៖ (២) សួសំណួរបញ្ជាក់ច្បាស់លាស់អំពីអ្វីដែលគេមិនយល់ច្បាស់។



អ្នកដែលស្តាប់គេបានល្អគឺជាអ្នកដែល ៖ (៣) និយាយសារឡើងវិញដោយពាក្យពេចន៍ខ្លួនឯងអំពីអ្វីដែលគេទើបនិយាយរួច។



អ្នកដែលស្ដាប់គេបានល្អគឺជាអ្នកដែល ៖ (៨) គិតអំពីអ្វីដែលគេចង់ដឹងបន្ថែម និងសួរសំណួរទៅតាមនោះដែរ។

**ខ្ទង់បំណង**

យុវជននឹងរៀនពីវិធីក្នុងការគ្រប់គ្រងអារមម្មណ៍របស់ខ្លួន និងកំណត់ទម្រង់នៃការគិតបែបអវិជ្ជមាន ដែលអាចនាំឲ្យមានអាកប្បកិរិយាគ្រោះថ្នាក់។

**ពេលវេលា**

៧៥ នាទី

**សម្ភារៈ :**

- ថតចម្លង "IS ១៥ក ៖ករណីសិក្សាអំពីការគិតបែបអវិជ្ជមាន" និង "IS ១៥ខ ៖ ការសម្តែងរឿងអំពីការគិតអវិជ្ជមាន" (ចំនួនគ្រប់គ្រាន់សម្រាប់ចំនួនពាក់កណ្តាលនៃក្រុម ដោយយុវជន នឹងបង្កើតក្រុមមានគ្នាពីរនាក់ដើម្បីអាន IS ទាំងពីរ)

**ការត្រៀម**

**សេចក្តីផ្តើម**

**ការស្វាគមន៍**

ស្វាគមន៍យុវជនដោយហៅឈ្មោះ។ ហុចតគ្នានូវបញ្ជីឈ្មោះចុះហត្ថលេខាវត្តមាន។

**សកម្មភាពមុនចាប់ផ្តើម**

ឲ្យអ្នកសម្របសម្រួលជាយុវជនជ្រើសរើសសកម្មភាពចាប់ផ្តើមមុននៅក្នុងតារាង។

**ការរំឭកមេរៀន**

តើមាននរណាបានប្រើជំនាញក្នុងការទំនាក់ទំនងបែបម៉ឺងម៉ាត់ដែរ ឬទេកាលពីសប្តាហ៍មុន? តើវាមានសារៈប្រយោជន៍ដែរ ឬទេ? តើវាមានការលំបាកដែរ ឬទេ?

តើមាននរណាបានប្រើជំនាញក្នុងការស្តាប់បានល្អដែរ ឬទេកាលពីសប្តាហ៍មុន? តើវាមានសារៈប្រយោជន៍ដែរ ឬទេ? តើវាមានការលំបាកក្នុងការប្រើជំនាញទាំងនេះដែរ ឬទេ?

**ការពិភាក្សា**

ពន្យល់ថា ថ្ងៃនេះយើងសិក្សាអំពីការគ្រប់គ្រងអារម្មណ៍។ បុគ្គលគ្រប់រូបទាំងអស់នៅលើផែនដីសុទ្ធតែមានថ្ងៃដែលគេមានអារម្មណ៍ពិបាក។ គ្មាននរណាផ្សេងអាចផ្លាស់ប្តូរជីវិតរបស់គេដើម្បីគេចផុតពីបញ្ហាបានឡើយ ប៉ុន្តែមនុស្សអាច ផ្លាស់ប្តូរ វិធីដែលគេប្រតិកម្មទៅនឹងបញ្ហារបស់ខ្លួន។ ឲ្យក្រុមនីមួយៗផ្តល់នូវឧទាហរណ៍អំពីអារម្មណ៍លំបាកៗ។ ការរៀបរាប់នេះមានលក្ខណៈដូចខាងក្រោម ៖

- ក្រៀមក្រំ
- ដូចឆ្កួត
- ខឹងសម្បារ
- ក្បត់អារម្មណ៍
- ខឹងខ្លាំង
- តប់ប្រមល់
- អស់សង្ឃឹម
- អស់ក្តីស្រលាញ់

ពន្យល់ថា មនុស្សគ្រប់រូបនឹងជួបប្រទះបញ្ហាជាច្រើននៅក្នុងជីវិត។ ជានិច្ចកាលវាមិនមែនសុទ្ធតែ អាចផ្លាស់ប្តូរកាលៈទេសៈ ក្នុងជីវិតរបស់បុគ្គលម្នាក់ ដើម្បីដោះស្រាយបញ្ហាបាននោះទេ ប៉ុន្តែ អាចផ្លាស់ប្តូររបៀបដែលបុគ្គលម្នាក់ប្រតិកម្មទៅនឹងបញ្ហាទាំងនោះបាន។

ពន្យល់ថា វិធីដែលមនុស្សគិតអំពីបញ្ហាមានឥទ្ធិពលខ្លាំងណាស់។ ប្រាប់ទៅយុវជនថា អ្នកនឹងត្រូវអានតារាងមួយរៀបរាប់អំពីទម្រង់នៃការគិតអវិជ្ជមានចំនួនបួនបែបដែលធ្វើឲ្យបញ្ហាប្រែក្លាយកាន់តែអាក្រក់ទៅ។ ឲ្យយុវជនបិទភ្នែករបស់គេអំឡុងពេលកំពុងអាន ហើយជាមួយឧទាហរណ៍នីមួយៗ ឲ្យគេគិតពីឧទាហរណ៍មួយពីជីវិតផ្ទាល់ខ្លួនរបស់គេ។

**ការគិតជ្រុលនិយម**

- ជួនកាល មនុស្សនឹងចាប់ផ្តើមគិតបែបជ្រុលនិយម។
- ឧទាហរណ៍ថា សិស្សម្នាក់ដែលខូចកង់នៅតាមផ្លូវទៅសាលានិយាយថា "អ្វីគ្រប់យ៉ាងនឹងមានបញ្ហាពេញមួយថ្ងៃនេះមិនខាន" នៅពេលដែលមានរឿងតូចមួយកើតមានប៉ុណ្ណោះ។ ឬយុវជនដែលបានពិន្ទុមិនល្អ និយាយថា "នេះគឺជារឿងដែលអាក្រក់បំផុតដែលបានកើតមានចំពោះខ្ញុំ"។

**ការស្តីបន្ទោសខ្លួនឯង**

- ពេលខ្លះមនុស្សស្តីបន្ទោសខ្លួនឯងចំពោះរឿងដែលគេមិនអាចគ្រប់គ្រងបាន។
- ឧទាហរណ៍ថា ក្មេងស្រីម្នាក់គិតថា វាជាកំហុសរបស់នាងដែលគ្រួសារនាងមានភាពក្រីក្រ។

**ការមើលឃើញតែខាងអាក្រក់**

- ពេលខ្លះមនុស្សនឹងផ្តោតទៅលើតែទិដ្ឋភាពអាក្រក់នៃបញ្ហាប៉ុណ្ណោះ។
- ឧទាហរណ៍ដូចជា ក្មេងប្រុសម្នាក់ចូលចិត្តក្មេងស្រីម្នាក់។ គេសម្គាល់តែនៅពេលដែលនាងមិនយកចិត្តទុកដាក់ជាមួយគេប៉ុណ្ណោះ ហើយមិនដែលគិតពីពេលដែលនាងញញឹមដាក់គេទេ។

**ព្យាករណ៍តែពីអនាគតអាក្រក់**

- ពេលខ្លះមនុស្សមើលឃើញបញ្ហាមួយ ហើយគេស្រមៃថា វានឹងជះឥទ្ធិពលអាក្រក់លើជីវិតគេទាំងមូល ដោយមិនមានភាពជាក់លាក់ និងមើលលើភស្តុតាងដែលមានទេ។
- ឧទាហរណ៍ថា ក្មេងស្រីម្នាក់គិតថា ជីវិតទាំងមូលរបស់នាងត្រូវបំផ្លាញអស់ហើយដោយគ្រាន់តែប្រឡងមិនជាប់។

## ផ្គូរផ្គងករណីសិក្សា

ឲ្យយុវជនបើកភ្នែក និងបែងចែកក្រុមដែលមានគ្នាពីរនាក់។ ចែកជូនក្រុមនីមួយៗនូវ "IS ១៥កៈ ករណីសិក្សាអំពីការគិតអវិជ្ជមាន"។ ឲ្យសិស្សអានករណីសិក្សា ហើយឲ្យគេផ្គូរផ្គងទៅនឹងទម្រង់នៃការគិតអវិជ្ជមានដែលគេបានរៀបរាប់។ (ត្រូវគូសបន្ទាប់ភ្ជាប់នៅលើទំព័រសៀវភៅតែម្តង។ ចម្លើយគឺ ១ គ, ២ ខ, ៣ ក, ៤ ឃ

## ការគិតវិជ្ជមាន

ពន្យល់ថា វិធីមួយក្នុងការដោះស្រាយបញ្ហាគឺត្រូវប្តូរចេញនូវទម្រង់នៃការគិតអវិជ្ជមានដោយជំនួសវិញនូវទម្រង់នៃការគិតបែបវិជ្ជមាន។ គ្មានការគិតវិជ្ជមានណាដែលនឹងដោះស្រាយបញ្ហា

នេះទេ។ ប៉ុន្តែនៅពេលដែលវាក្លាយមកជាបញ្ហាតូចមួយ ការគិតវិជ្ជមានអាចជួយបាន។ អានចម្លើយខាងក្រោមនេះឲ្យ ឮៗ៖

**ការគិតបែបជ្រុលនិយម និងការមើលឃើញតែផ្លូវអាក្រក់**

- ចងចាំពីជំនាញផ្ទាល់ខ្លួនរបស់អ្នក ឬអ្វីៗដែលល្អនៅក្នុងជីវិតរបស់អ្នក។ បន្ទាប់មកផ្តោតលើរឿងទាំងនោះ។
- ព្យាយាម កុំប្រើពាក្យមួយចំនួន ដូចជា អ្វីគ្រប់យ៉ាង ជានិច្ចកាល មិនដែល ឲ្យសោះនៅពេលដែលបរិយាយពីបញ្ហានានា។ ចង់ចាំថា បញ្ហានៅថ្ងៃនេះ អាចដោះស្រាយចេញនៅថ្ងៃស្អែក។
- មិនត្រូវរៀបរាប់ពីអ្វីដែលជាកំហុសឡើយ។ នៅពេលដែលមនុស្សចាប់ផ្តើមរៀបរាប់ពីបញ្ហា គឺពួកគេកំពុងធ្វើឲ្យបញ្ហានីមួយៗកាន់តែធំឡើងៗ ប្រៀបដូចបញ្ហានោះជាផ្នែកមួយនៃទម្រង់គិតអញ្ចឹង។

**ស្តីបន្ទោសខ្លួនឯង**

- ការស្តីបន្ទោសខ្លួនឯងកម្រនឹងជួយដោះស្រាយបញ្ហាណាស់។
- ចងចាំថា បញ្ហាភាគច្រើនគឺជាលទ្ធផលនៃមនុស្ស និងព្រឹត្តិការណ៍ជាច្រើនមិនមែនជាបុគ្គលតែម្នាក់នោះទេ។
- ត្រូវយកចិត្តទុកដាក់លើដំណោះស្រាយឲ្យបានច្រើនជាងការស្តីបន្ទោស។

**ការព្យាករណ៍អនាគតមិនល្អ**

- ចាំទុកថា មិនមាននរណាម្នាក់អាចទស្សន៍ទាយត្រូវពីអនាគតឡើយ។ ដកដង្ហើមវែងៗ ហើយចាំថា ថ្ងៃស្អែកគឺជាថ្ងៃថ្មី។ អ្នកអាចនឹងភ្ញាក់ឡើង ហើយឮព័ត៌មានល្អ។

## ទម្រង់នៃការគិតអវិជ្ជមាន និងអាកប្បកិរិយាគ្រោះថ្នាក់

ពន្យល់ថា ទម្រង់នៃការគិតអវិជ្ជមាន អាចបង្កើនអាកប្បកិរិយាគ្រោះថ្នាក់។ អានរឿងខាងក្រោមឲ្យឮៗ៖

**រឿងទី ១ ៖**

ប តែងតែគិតជ្រុលនិយម។ នៅពេលដែល ប ត្រូវចាកចេញពីសាលារយៈពេលពីរខែ ដើម្បីប្រមូលផលស្រូវ គាត់គិតថាជីវិតទាំងមូលរបស់គេនឹងត្រូវបំផ្លាញ។ គាត់គិតថា គ្មានថ្ងៃដែលគេត្រឡប់មករៀនវិញទេ ហើយផ្ទុយមកវិញបែរជាគិតថាគេអាចរកការងារធ្វើបានលុះត្រាតែធ្វើចំណាកស្រុកប៉ុណ្ណោះ។

សំណាងល្អ បងស្រីរបស់គេបានជួយដល់គេឲ្យមើលឃើញអ្វីគ្រប់យ៉ាងក្នុងផ្លូវវិជ្ជមានវិញ។ គាត់បានណែនាំប្រាប់គេថា យុវវ័យមួយចំនួនបានចាកចេញពីសាលារៀនមួយរយៈ ហើយបន្ទាប់មកក៏ត្រឡប់ទៅរៀនវិញ។ នាងជួយដល់គេឲ្យអនុវត្តការអាន ដើម្បីឲ្យគេមាន អារម្មណ៍ថា បានត្រៀមខ្លួនរួចជាស្រេចដើម្បីត្រឡប់ទៅរៀនវិញ។

**រឿងទី ២ ៖**

ព តែងតែស្តីបន្ទោសខ្លួនឯងដោយសារតែបញ្ហាគ្រួសាររបស់នាង។ នៅពេលដែលប្អូនស្រីរបស់នាងមានគ្រោះថ្នាក់ដោយជិះម៉ូតូរបស់គាត់ ហើយត្រូវចូលក្នុងមន្ទីរពេទ្យ ព មានអារម្មណ៍ ទទួល

ខុសត្រូវចំពោះការដែលមិនបានរំឭកដល់ប្អូនស្រីរបស់នាង។ ដោយសារតែ ព មានអារម្មណ៍ទទួលខុសត្រូវ នាងបានយល់ព្រមតាមមីងរបស់នាងនៅពេលដែលមីងរបស់នាងឲ្យយោបល់ថា ព គួរទៅធ្វើការនៅក្នុងផ្ទះបនដើម្បីរកប្រាក់សង់ថ្លៃព្យាបាល។

សំណាងល្អ ប្អូនស្រីរបស់ ព បានឮអំពីផែនការនោះ។ នាងប្រាប់ទៅ ព ថា គាត់មិនចាំបាច់ទទួលខុសត្រូវចំពោះគ្រោះថ្នាក់នេះទេ ហើយ ព នឹងធ្វើការសម្រេចចិត្តដ៏អាក្រក់មួយប្រសិនបើនាងទៅធ្វើការនៅផ្ទះបននោះ។

## ការសម្ដែងរឿង

ឲ្យអ្នកចូលរួមអានរឿងនៅលើ "ES១៥ខ ៖ ការសម្ដែងរឿងអំពីការគិតបែបអវិជ្ជមាន" ។ ឲ្យយុវជនបែងចែកក្រុមមានគ្នាពីរនាក់។ ហើយម្នាក់សម្ដែងជា ម និងម្នាក់ទៀតសម្ដែងជាបងប្រុសរបស់គាត់។ ឲ្យបងប្រុសព្យាយាមផ្ដល់យោបល់ជាមធ្យោបាយវិជ្ជមានមួយក្នុងការសំឡឹងមើលលើបញ្ហា។ ឲ្យបងប្រុស ព្យាយាមបញ្ចុះបញ្ចូលអ្នកដែលសម្ដែងជា ម ។
នៅពេលដែល គេបានធ្វើកិច្ចការនេះបាន ១០ នាទី ឲ្យអ្នកចូលរួមចែករំលែកឧទាហរណ៍មួយចំនួនអំពីមធ្យោបាយវិជ្ជមានមួយចំនួនដោយសំឡឹងមើលលើបញ្ហាមួយចំនួន។

## កំណត់ហេតុមេរៀន

ឲ្យក្រុមនីមួយៗសរសេរ ឬគូររូបនៅក្នុងសៀវភៅកំណត់ហេតុរបស់គេរយៈពេល ១០ នាទី។ ឲ្យពួកគេ ព្យាយាមគិតអំពីពេលវេលា ឬអាចជាស្ថានភាពថ្មីៗមួយដែលពេលនោះគេពិតជាមានអារម្មណ៍អាក្រក់បំផុត ហើយសរសេរអំពីវិធីដែលគេអាចគ្រប់គ្រងអារម្មណ៍បន្តិចម្ដងៗឲ្យមានភាពល្អប្រសើរឡើង។ ឲ្យពួកគេគិតអំពីវិធានការជាក់លាក់មួយដែលគេបានចាត់ ឬអាចនឹងចាត់ និងបុគ្គលដែលត្រូវបានជួយ។ ឲ្យគេពិចារណាថា តើគេធ្លាប់បានប្រើប្រាស់ទម្រង់នៃការគិតបែបអវិជ្ជមានកាលពីមុនដែរឬទេ និងគិតថា តើគេអាចប្រើប្រាស់ទម្រង់នៃការគិតបែបវិជ្ជមាននៅថ្ងៃអនាគតដែរ ឬយ៉ាងណា។

### សង្ខេបមេរៀន

- ការគិតអវិជ្ជមានអាចធ្វើឲ្យបញ្ហាកាន់តែអាក្រក់
- ខាងក្រោមនេះគឺជាទម្រង់នៃការគិតបែបអវិជ្ជមានជាទូទៅ ៖
  - ការគិតបែបជ្រុលនិយម
  - ការស្ដីបន្ទោសខ្លួនឯង
  - សំឡឹងមើលតែផ្លូវអាក្រក់
  - ព្យាករណ៍តែអំពីអនាគតអាក្រក់
- ការគិតបែបវិជ្ជមានអាចជួយអ្នកឲ្យដោះស្រាយបញ្ហាបាន ។

## ការបិទបញ្ចប់

ប្រាប់ឲ្យយុវជនសរសេរ ឬសួរសំណួរ និង/ឬ ផ្តល់ជាព័ត៌មានត្រឡប់ និងប្រគល់ឲ្យទៅអ្នកសម្របសម្រួលដោយមិនបាច់បញ្ចេញឈ្មោះ។

អរគុណដល់យុវជនទាំងអស់គ្នាដែលបានមករៀន។ បញ្ជាក់ឡើងវិញអំពីការប្រជុំភ្លឺបពេលក្រោយ។ ប្រាប់ពួកគេថា ពួកគេទទួលបានផ្កាយមួយទៀតសម្រាប់ការចូលរួមក្នុងម៉ោងសិក្សានេះ។ ឲ្យយុវជន ៖

- ព្យាយាមស្វែងយល់ អំពីទម្រង់នៃការគិតបែបអវិជ្ជមាន រហូតទាល់តែការប្រជុំបន្ទាប់ទៀត។
- ព្យាយាមប្រើប្រាស់ការគិតបែបវិជ្ជមាន ហើយពេលត្រឡប់មកម៉ោងសិក្សាក្រោយចូរប្រាប់ដល់ពួកយើងវិញថា តើអាចធ្វើបានដែរ ឬទេ។

អ្នកសម្របសម្រួលអាចសួរយុជនឲ្យសរសេរការណែនាំនេះលើក្រដាសយកទៅផ្ទះដើម្បីរំឭក។ រំឭក។

# ១៥ IS ១៥ក ÷ ករណីសិក្សាអំពីការគិតអវិជ្ជមាន

ផ្គូរផ្គងរឿងខាងក្រោម ទៅនឹងទម្រង់នៃការគិតអវិជ្ជមាន។ អ្នកនឹងត្រូវគូសបន្ទាប់ឡើងលើចុះក្រោមក្នុងទំព័រនេះ។

| | |
|---|---|
| ១. មនុស្សម្នាក់មានសារៈសំខាន់សម្រាប់ម នៅសាលារៀន។ ពេលនេះគេគិតថា មនុស្សគ្រប់គ្នាស្អប់គេ។ | ក . ការព្យាករណ៍ពីអនាគតមិនល្អ |
| ២. កត់សម្គាល់តែពេលដែលគ្រូរិះគន់នាងប៉ុណ្ណោះ។ នាងមិនដែលនឹកឃើញដល់ការសរសើររបស់គ្រូទេ។ | ខ. មើលឃើញតែក្នុងផ្លូវអាក្រក់ |
| ៣. ល ជឿជាក់ថា គេអាចជួបតែអនាគតអាក្រក់ប៉ុណ្ណោះ។ | គ. ការគិតបែបជ្រុលនិយម គិតអ្វីដែលអាក្រក់បំផុត។ |

ម បានធ្វើចំណាកស្រុកទៅទីក្រុងធំមួយ ហើយបានធ្វើការងារនៅក្នុងរោងចក្រធំមួយ។ គេធ្វើការ ១៨ ម៉ោងក្នុងមួយថ្ងៃ ហើយដេកនៅក្នុងរោងចក្រ។ គេបានធ្វើការអស់រយៈពេល បីខែ ហើយមិនទទួលបានប្រាក់កម្រៃឡើយ។ ថៅកែរោងចក្រនិយាយថា ម បានជំពាក់ ប្រាក់ថ្លៃស្នាក់នៅ ហើយនឹងត្រូវធ្វើការងារពេញមួយឆ្នាំ។ ម បានទូរស័ព្ទទៅកាន់បងប្រុសរបស់ខ្លួននៅក្នុងភូមិកំណើត និងបានិយាយដូចខាងក្រោម ៖

"វាជាកំហុសរបស់ខ្ញុំ ពីព្រោះខ្ញុំជាកម្មករដែលមិនមានបទពិសោធន៍។"

"នេះជាប្រភេទការងារដែលខ្ញុំនឹងបានធ្វើ"។ គ្មាននរណាម្នាក់ដែលនឹងជួលខ្ញុំឲ្យធ្វើការទេ។"

"មិត្តភក្តិរបស់យើងម្នាក់ ដែលរៀនសាលាជាមួយគ្នាពីមុន ធ្វើការនៅរោងចក្រមួយទៀត ហើយគេបានប្រាប់ថា គេកំពុងរកបុគ្គលិក ហើយទទួលបានប្រាក់ខែទៀងទាត់។ គេបានប្រាប់ថា រោងចក្រដែលគេធ្វើការនោះ មានចុះបញ្ជីការជាមួយរដ្ឋត្រឹមត្រូវ។ ប៉ុន្តែគេនឹងមិនជួលមនុស្សដូចជាខ្ញុំទេ។"

"គ្មានផ្លូវដែលរកការងារផ្សេងបានធ្វើទេ។ គេផ្សេងនឹងដឹងថា ខ្ញុំបានធ្វើការទីទៅនេះ ហើយនឹងមើលងាយខ្ញុំ។"

# មេរៀនទី១៦ ÷ ការគ្រប់គ្រងអារម្មណ៍របស់យើង (ជំនាញគ្រប់គ្រងអារម្មណ៍) ១៦

## វត្ថុបំណង

យុវជននឹងយល់អំពីវិធានការអ្វីដែលត្រូវចាត់ឡើងដើម្បីឆ្លើយតបយ៉ាងវិជ្ជមានទៅកាន់អារម្មណ៍ពិបាកៗដូច្នេះគេមិនបានបង្កទុក្ខទោសដល់ខ្លួនឯង និងអ្នកដទៃ។

## ពេលវេលា

៧៥ នាទី

**សម្ភារៈ :**

- ក្រដាសផ្ទាំងធំ
- ប៊ិចក្រហម និងប៊ិចខៀវ
- ឯកសារយោង "ឯ ១៦ក ៖ ឧទាហរណ៍នៃតារាង ស្ថិតិអារម្មណ៍" សម្រាប់សកម្មភាព"

## សេចក្តីផ្តើម

**ការស្វាគមន៍**

ស្វាគមន៍យុវជនដោយហៅឈ្មោះ។

ហុចតគ្នានូវបញ្ជីឈ្មោះចុះហត្ថលេខាវត្តមាន។

**សកម្មភាពមុនចាប់ផ្តើម**

ឲ្យអ្នកសម្របសម្រួលជាយុវជនជ្រើសរើសសកម្មភាពចាប់ផ្តើមមុននៅក្នុងតារាង។

**ការរំឭកមេរៀន**

តើមាននរណាបានកត់សម្គាល់ឃើញមានទម្រង់នៃការគិតបែបអវិជ្ជមាននៅក្នុងជីវិតប្រចាំថ្ងៃរបស់គេដែរ ឬទេ?

តើមាននរណាសាកល្បងប្រើប្រាស់ការគិតបែបវិជ្ជមានដែរ ឬទេ? តើវាជួយបានដែរ ឬទេ?

## ការពិភាក្សា

ពន្យល់ថា កាលពីម៉ោងសិក្សាមុន និយាយអំពីទិដ្ឋភាពដែលមនុស្សគ្រប់គ្នាជួបប្រទះបញ្ហា និងអំពីថា តើបញ្ហាទាំងនេះអាចធ្វើមនុស្សមានអារម្មណ៍ពិបាកដោយរបៀបណា។ ពន្យល់ថា វាមានការលំបាកណាស់ក្នុងការផ្លាស់ប្តូរជីវិតរបស់អ្នកដើម្បីគេចវេសពីបញ្ហានោះ ប៉ុន្តែវាអាចផ្លាស់ប្តូររបៀបដែលអ្នកឆ្លើយតបទៅនឹងបញ្ហាបាន។

រំឭកយុវជនអំពីតារាងអំពីអារម្មណ៍អវិជ្ជមានដែលយុវជនកើតមាន។ សរសេរការរៀបរាប់នេះម្តងទៀតនៅផ្នែកម្ខាងទៀតនៃក្រដាសផ្ទាំងធំ។ អារម្មណ៍ទាំងនេះរួមមាន ៖

- ក្រៀមក្រំ
- ដូចឆ្កួត
- ខឹងសម្បារ
- ក្បត់អារម្មណ៍
- ខឹងខ្លាំង
- តប់ប្រមល់

- អស់សង្ឃឹម
- អស់ក្តីស្រលាញ់

ពេលនេះ សួរថា តើសកម្មភាពអវិជ្ជមានអ្វីខ្លះដែលយុវវ័យសម្តែងចេញពេលខ្លះ នៅពេលដែលគេមានអារម្មណ៍បែបនេះ។ ប្រសិនបើឧទាហរណ៍ខាងក្រោមមិនត្រូវបានលើកឡើង នោះចូលបន្ថែមទៅក្នុងតារាង

- ចូលប្រឡូកក្នុងការវាយតប់
- ធ្វើការសម្រេចចិត្តមិនល្អ
- វាយនរណាម្នាក់
- នៅក្នុងផ្ទះរាល់ថ្ងៃ
- យំស្រែក និងបដិសេធន៍មិននិយាយជាមួយអ្នកផ្សេង
- កាត់សាច់ខ្លួនឯង
- ឈប់បរិភោគអាហារ
- ស្តីបន្ទោសអ្នកដទៃ
- ធ្វើអត្តឃាត
- សម្លុតគេឯង
- រត់គេចពីផ្ទះដោយគិតថា គេចចេញពីបញ្ហា
- ផឹកគ្រឿងស្រវឹងច្រើន
- សេពគ្រឿងញៀន
- ហ៊ានប្រថុយប្រថាន ។

សរសេរសកម្មភាពទាំងនេះនៅលើក្រដាសផ្ទាំងធំដែលអ្នកគ្រប់គ្នាអាចមើលឃើញ។

ឲ្យបិចពីរទៅ យុវជន និងឲ្យគេគូសរង្វង់លើសកម្មភាពណាដែលផ្តល់ទុក្ខទោសដល់បុគ្គលផ្ទាល់ជាពណ៌ក្រហម និងសកម្មភាពណាដែលធ្វើទុក្ខទោសដល់អ្នកដទៃជាពណ៌ខៀវ។ សកម្មភាពខ្លះអាចត្រូវគូសទាំងពីរពណ៌ក្រហម និងខៀវ។

ឧទាហរណ៍ អំពីរបៀបដែលតារាងមានទ្រង់ទ្រាយដូចម្តេចនៅពេលបញ្ចប់នោះ សូមមើល "IS ១៦ក៖ ឧទាហរណ៍អំពីតារាងអំពីអារម្មណ៍"។

ពេលនេះ ឲ្យក្រុមមើលម្តងទៀតលើតារាង។ សួរថា "តើមានសកម្មភាពណាខ្លះនៅក្នុងតារាងនេះដែលអាចនឹងនាំឲ្យយុវវ័យស្ថិតក្នុងគ្រោះថ្នាក់នៃការជួញដូរដែរ ឬទេ?" ឲ្យយុវជនផ្តល់ចម្លើយរបស់គេប៉ុន្តែប្រសិនបើគេមានពេលវេលាមិនស្រួលក្នុងការគិតអំពីឧទាហរណ៍ សួរទៅគេថា តើការរត់ចេញពីផ្ទះ ការផឹកសុរាច្រើនហួស ធ្វើសេចក្តីសម្រេចចិត្តមិនល្អ ឬការសេពគ្រឿងញៀនអាចបង្កើនហានិភ័យនៃការជួញដូរដែរ ឬទេ?

## ជំហានក្នុងការដោះស្រាយបញ្ហាអារម្មណ៍ពិបាក

ពន្យល់ថា ម៉ោងសិក្សានេះ គឺនិយាយអំពីសកម្មភាពដែលគេអាចអនុវត្តនៅពេលដែលគេមានអារម្មណ៍អវិជ្ជមាន។សកម្មភាពទាំងនេះគឺជាជម្រើសផ្សេងទៀតដែលមិនធ្វើទុក្ខទោសដល់ពួកគេ និងអ្នកដទៃ។ អារម្មណ៍អវិជ្ជមានគឺជារឿងដែស្មុគស្មាញណាស់ ដូច្នេះវាពិបាកក្នុងការបង្ហាប់អំពី

អ្វីមួយដែលធ្វើឲ្យនរណាម្នាក់មានអារម្មណ៍ប្រសើរជាងមុនគ្រប់ពេលវេលា។ ប៉ុន្តែការរៀបរាប់ខាងក្រោមនេះអាចជួយបាន ៖

**ជំហានទី ១ ការសម្គាល់ថា តើអ្នកមានអារម្មណ៍ដូចម្តេច**

ពន្យល់ថា នៅពេលដែលមនុស្សមានអារម្មណ៍ក្រៀមក្រំ ឬដូចឆ្កួតនោះ គេអាចនឹងមានអារម្មណ៍មានពិរុទ្ធ ឬក្រៀមក្រំដែលគេមានអារម្មណ៍ក្នុងទិដ្ឋភាពនេះ ដូច្នេះគេធ្វើហាក់បីដូចជាមិនមានអ្វីកើតឡើង។ ការធ្វើបែបនេះ មិនបានជួយដល់មនុស្ស ក្នុងការដោះស្រាយបញ្ហាអារម្មណ៍ឡើយ។

**អានឲ្យឮៗ ៖**

ស្រមៃថា មិត្តភក្តិម្នាក់នៅសាលារៀនមិនទាន់បានធ្វើកិច្ចការផ្ទះរបស់នាង ហើយសុំចម្លងចម្លើយរបស់អ្នក។ អ្នកមិនចង់យល់ព្រមទេ ប៉ុន្តែអ្នកបានឲ្យចម្លើយកិច្ចការផ្ទះរបស់អ្នកទៅនាង។ វាធ្វើឲ្យអ្នកមានអារម្មណ៍ខឹងខ្លាំង ប៉ុន្តែអ្នកមិនចង់បញ្ចេញឲ្យគេដឹង។ ថ្ងៃក្រោយអ្នកបាននិយាយជាមួយមិត្តផ្សេងទៀតរបស់អ្នក ហើយអ្នកបានប្រាប់មិត្តអ្នកពីរឿងទាំងអស់ថា មិត្តម្នាក់របស់អ្នកនោះបានលួចចម្លង។ ពេលនេះមិត្តរបស់អ្នកម្នាក់នោះបានខឹងអ្នក ហើយអ្នកមានបញ្ហាក្នុងទំនាក់ទំនងមួយនេះ។ អ្នកបានបង្កឲ្យបញ្ហាកាន់តែធំឡើងៗដោយធ្វើឲ្យពាក់ព័ន្ធដល់អ្នកដទៃ។ ប្រសិនបើអ្នកបានដឹងពីការមានអារម្មណ៍ខឹងបែបនេះពីដំបូង អ្នកប្រហែលជាមិនធ្វើឲ្យបញ្ហានេះរីកធំឡើងបែបនេះទេ។

សួរថា តើមាននរណាម្នាក់ អាចស្រមៃអំពីឧបទ្ទវហេតុតូចជាងនេះ ដែលព្យាយាមបដិសេធន៍អារម្មណ៍ ដែលបង្កឲ្យមានបញ្ហាកាន់តែធំឡើងនៅពេលក្រោយដែរ ឬទេ។

ពន្យល់ថា តើអ្នកមានអារម្មណ៍របៀបណា គឺជាជំហានដំបូងសម្រាប់ការដោះស្រាយបញ្ហានៃការមានអារម្មណ៍លំបាក។

**ជំហានទី ២. ការយល់ថា ហេតុអ្វីបានជាអ្នកមានអារម្មណ៍បែបនេះ។**

ពន្យល់ថា ពេលខ្លះមនុស្សមានអារម្មណ៍រំជួលចិត្ត ហើយគេមិនដឹងថាហេតុអ្វីបានជាគេមានអារម្មណ៍បែបនេះទេ។

ឧទាហរណ៍ថា ខ មានអារម្មណ៍តប់ប្រមល់ខ្លាំងនៅពេលដែលនាងកំពុងគិតអំពីការឈប់ទៅសាសាលារៀន ដើម្បីធ្វើការងារនៅក្នុងស្រែចម្ការ។ នេះដោយសារតែនាងមានភាពក្រីក្រ ហើយ ក្មេងក្មេងដទៃចំអក់ឡកឡើយដល់នាងនៅសាលា។

ឲ្យយុវជនគិតអំពីមូលហេតុអ្វីដែលនាំឲ្យពួកគេមានអារម្មណ៍ថា ជាការរំជួលចិត្តដ៏លំបាកមួយ។ ឲ្យពួកគេ រំឭកឡើងវិញ ពេលណាដែលពួកគេ មានអារម្មណ៍រំជួលចិត្តបែបនេះជាលើកដំបូង។ សួរពួកគេផងថា តើគេមានអារម្មណ៍រំជួលចិត្ត លើកដំបូងបែបនេះ ដោយសារតែលទ្ធផលនៃព្រឹត្តិការណ៍លំបាកណាមួយ (ឧទាហរណ៍ ការវាយតប់មួយ) ឬថា តើដោយសារតែលទ្ធផលនៃការផ្លាស់ប្តូរជីវិតរបស់គេ។

ពន្យល់ថា ការយល់ពីមូលហេតុដែលគេមានអារម្មណ៍បែបនេះគឺជាជំហានទីពីរសម្រាប់ដោះស្រាយបញ្ហាអារម្មណ៍ពិបាក។

**ជំហានទី ៣ ៖ ជ្រើសរើសសកម្មភាពមួយបែប ដែលធ្វើឲ្យអ្នកមានអារម្មណ៍ប្រសើរជាងមុន ហើយមិនធ្វើទុក្ខទោសដល់អ្នកដទៃ**

សួរទៅយុវជនថា តើគេអាចគិតអំពីមធ្យោបាយដែលយុវជនអាចធ្វើបែបនេះបានដែរ ឬទេ។ សរសេរយោបល់របស់គេ ហើយប្រសិនបើគំនិតខាងក្រោមនេះមិនត្រូវបានលើកឡើងទេនោះ សូមបន្ថែម៖

- គិតអំពីវាយតប់
- ដើរ
- ទៅលេងកីឡា
- ធ្វើលំហាត់ប្រាណ
- សរសេរចូលក្នុងសៀវភៅកំណត់ហេតុ
- ជជែកជាមួយមិត្តម្នាក់
- ចំណាយពេលខ្លះគេចចេញពីបញ្ហា
- ជួយអ្នកផ្សេងទៀតដែលមានបញ្ហាដូចគាត់
- ព្យាយាមដោះស្រាយស្ថានភាពដោយការអត់ធ្មត់ ។

## ការពិភាក្សា

សួរយុវជនថា “តើអ្នកគិតដូចម្តេចអំពីជំហានទាំងបីសម្រាប់ការដោះស្រាយជាមួយនឹងអារម្មណ៍ពិបាកៗ?

- តើគិតថាវាមានលក្ខណៈសមហេតុផលដែរ ឬទេ? ហេតុអ្វីមែន ឬហេតុអ្វីមិនមែន?
- តើអ្នកអាចប្រើប្រាស់វានៅក្នុងជីវិតរស់នៅផ្ទាល់ខ្លួនរបស់អ្នកបានដែរ ឬទេ? ហេតុអ្វីបាន ឬ ហេតុអ្វីមិនបាន?
- តើពេលណាដែលមានអំណោយផលល្អសម្រាប់ប្រើប្រាស់វា?

## អារម្មណ៍លំបាក និងហានិភ័យនៃការជួញដូរមនុស្ស

ពន្យល់ថា អារម្មណ៍ពិបាកអាចធ្វើឲ្យមនុស្ស ធ្វើសេចក្តីសម្រេចចិត្ត ដោយមិនឆ្លៀសវៃ ដែលបង្កើន អាកប្បកិរិយាប្រកបដោយហានិភ័យ។ អានឲ្យឮៗនូវសេចក្តីពន្យល់អំពីស្ថានភាពរបស់ ខ ដូចខាងក្រោម៖

ខ មានអារម្មណ៍តប់ប្រមល់ ពីព្រោះនាងត្រូវបានគេចំអកឡកឡឺយថា ជាកូនអ្នកក្រីក្រម្នាក់។ ក៏ប៉ុន្តែការចាកចេញពីសាលារៀនមានន័យថា នាងមានលទ្ធភាពទាបក្នុងការទទួលបានការងារល្អធ្វើនៅពេលអនាគត។ វានឹងមានន័យថា ទំនងជានៅតែក្រីក្រពេញមួយជីវិតរបស់នាង និងមានភាពងាយរងគ្រោះកាន់តែខ្លាំង ចំពោះមនុស្សដែលផ្តល់ការងារប្រើជំនាញទាបដែលជាក់ស្តែងគេមានបំណងជួញដូរនាងប៉ុណ្ណោះ។ ខាងក្រោមនេះ ជាឧទាហរណ៍ផ្សេងទៀតអំពី របៀបដែលអាររម្មណ៍លំបាកអាចបង្កើនហានិភ័យនៃការជួញដូរ ៖

ស មានអារម្មណ៍អស់សង្ឃឹមពីព្រោះគេបានធ្វើការនៅការដ្ឋានសំណង់មួយកន្លែងជាការងារដែលគេមិនពេញចិត្តទាល់តែសោះ។ អ្នកគ្រប់គ្រងរបស់គេបានឲ្យថ្នាំមួយគ្រាប់ទៅគាត់លេបដែលគេនោះបានប្រាប់ថា នឹងធ្វើឲ្យគេមានអារម្មណ៍បានប្រសើរឡើង។ តើការលេបថ្នាំអាចបង្កើន

ហានិភ័យនៃការជួញដូរសម្រាប់ ស នៅថ្ងៃអនាគតដោយរបៀបណា?

ល មានអារម្មណ៍ខឹង ពីព្រោះឪពុកម្តាយរបស់នាង មិនចង់ឲ្យនាងជួបជាមួយនឹងមិត្តប្រុសថ្មីរបស់នាងទេ។ មិត្តប្រុសរបស់នាងមានការងារឲ្យនាងធ្វើនៅក្នុងទីប្រជុំជនផ្សេងទៀត ដូច្នេះ នាងអាចឯករាជ្យតែឯងបាន។ តើការផ្លាស់ប្តូរទីកន្លែងអាចបង្កើនហានិភ័យនៃការជួញដូរ សម្រាប់ ល ដោយរបៀបណា?

ចងចាំថា មនុស្សគ្រប់រូបមានអារម្មណ៍ពិបាកចិត្តពេលខ្លះ។ យើងមិនបានវិនិច្ឆ័យលើ ម ឋ ស ឬ ល ចំពោះការមានអារម្មណ៍ខឹង ឬអស់សង្ឃឹម ឬតប់ប្រមល់នោះទេ។ អ្វីដែលសំខាន់នោះគឺត្រូវឆ្លើយតប ទៅនឹងអារម្មណ៍លំបាកទាំងនោះក្នុងទិដ្ឋភាពវិជ្ជមានដែលមិនធ្វើទុក្ខទោសដល់ខ្លួនអ្នក ឬអ្នកដទៃ។

## ការសម្តែងរឿង

ឲ្យយុវជនគិតអំពីរឿងមួយដើម្បីសម្តែង។ រឿងនេះនឹងត្រូវសម្តែងពីរដង។ ឲ្យយុវជនគិតអំពីរឿងមួយដែលអារម្មណ៍អវិជ្ជមាននាំឲ្យកុមារប្រឈមទៅនឹងហានិភ័យនៃការជួញដូរដែលមានការកើនឡើងជាលំដាប់។ ដំបូងអ្វីៗនឹងប្រែក្លាយពីអាក្រក់ទៅជាកាន់តែអាក្រក់។ ទីពីរ អ្វីៗនឹងមានភាពល្អប្រសើរឡើងវិញ។ ពិភាក្សារឿងមួយក្នុងចំណោមរឿងខាងក្រោមរយៈពេលប៉ុន្មាននាទី។ ឲ្យក្រុមពិភាក្សាអំពីតួអង្គផ្សេងៗគ្នា។ បន្ទាប់មកសួររកអ្នកស្ម័គ្រចិត្តដើម្បីសម្តែងរឿង។ (អាចមានតួរអង្គច្រើននៅក្នុងការសម្តែងនេះ)។

បន្ទាប់មក ឲ្យពួកគេគិតអំពីអ្វីដែលយុវវ័យអាចធ្វើដើម្បីឲ្យស្ថានភាពកាន់តែអាក្រក់ទៅ។
អ្នកអាចទៅមើលតារាងដែលបានធ្វើរួចពីមុន។

មួយនាទីក្រោយមក ឬលើសខ្វះបន្តិច សួររកអ្នកស្ម័គ្រចិត្តម្នាក់ឲ្យចូលរួមក្នុងការសម្តែង និងធ្វើសកម្មភាពដែលនាំឲ្យស្ថានភាពកាន់តែអាក្រក់។ ពីរ បីនាទីក្រោយមកទៀត បន្ថែមអ្នកស្ម័គ្រចិត្តម្នាក់ទៀតដែលបង្កឲ្យស្ថានភាពកាន់តែអាក្រក់បន្ថែមទៀត។ ប្រសិនបើសល់ពេលពិចារណាបន្ថែមមនុស្សចូលក្នុងការសម្តែងទៀត។

បញ្ឈប់ការសម្តែងនិងឲ្យយុវជន រៀបរាប់អំពី សកម្មភាពបែបអវិជ្ជមាន ដែលមនុស្សបានធ្វើនៅក្នុងការសម្តែង។

ពេលនេះ ធ្វើការសម្តែងឡើងវិញម្តងទៀត ប៉ុន្តែពេលនេះ ឲ្យអ្នកស្ម័គ្រចិត្តប្រើប្រាស់ជំហានទាំងបីសម្រាប់ដោះស្រាយបញ្ហាអារម្មណ៍ពិបាកដើម្បីធ្វើឲ្យស្ថានភាពកាន់តែប្រសើរឡើង។

**សង្ខេបមេរៀន**

- មនុស្សគ្រប់សុទ្ធតែមានអារម្មណ៍ពិបាកនៅក្នុងជីវិត។
- មានជំហានវិជ្ជមានជាច្រើនដែលអាចធ្វើបាននៅពេលដោះស្រាយបញ្ហាអារម្មណ៍លំបាក។
- ជំហានទាំងនេះរួមមាន ៖
  - ជំហានទី១៖ ការកត់សម្គាល់ថា តើអ្នកមានអារម្មណ៍ដូចម្តេច។
  - ជំហានទី ២៖ យល់ពីមូលហេតុដែលអ្នកមានអារម្មណ៍បែបនេះ។
  - ជំហានទី ៣៖ ជ្រើសរើសសកម្មភាពមួយបែប ដែលធ្វើឲ្យអ្នក មានអារម្មណ៍ប្រសើរ ហើយមិនធ្វើទុក្ខទោសដល់អ្នកដទៃ។
- អនុវត្តសកម្មភាពវិជ្ជមាន ដើម្បីដោះស្រាយ ជាមួយបញ្ហាអារម្មណ៍លំបាកៗ អាចធ្វើឲ្យអ្នកមានភាពស៊ូទ្រាំបានជាមួយនឹងការជួញដូរ។

## ការបិទវគ្គ

ប្រាប់ឲ្យយុវជនសរសេរ ឬសួរសំណួរ និង/ឬ ផ្តល់ជាព័ត៌មានត្រឡប់ និងប្រគល់ឲ្យទៅអ្នកសម្រសម្របសម្រួលដោយមិនបាច់បញ្ចេញឈ្មោះ។
អរគុណដល់យុវជនទាំងអស់គ្នាដែលបានមករៀន។ បញ្ជាក់ឡើងវិញអំពីការប្រជុំក្លឹបពេលក្រោយ។ ប្រាប់ពួកគេថា ពួកគេទទួលបានផ្កាយមួយទៀតសម្រាប់ការចូលរួមក្នុងម៉ោងសិក្សានេះ។
ឲ្យអ្នកចូលរួមព្យាយាមប្រើប្រាស់ជំហានទាំងបីរសម្រាប់ដោះស្រាយជាមួយនឹងអារម្មណ៍ពិបាកនៅក្នុងជីវិតប្រចាំថ្ងៃនៅមុនម៉ោងសិក្សាបន្ទាប់។

# ១៦ មេរៀនទី១៦ ÷ ការគ្រប់គ្រងអារម្មណ៍របស់យើង (ជំនាញគ្រប់គ្រងអារម្មណ៍)

| **ការសម្រេចចិត្តមិនល្អ** | **ការសម្រេចចិត្តមិនល្អ** |
| --- | --- |
| • មើលមិត្តភក្តិក្នុងផ្លូវហិង្សា | • យំ |
| • វាយតប់ជាមួយឪពុកម្តាយ | • នៅម្នាក់ឯងក្នុងបន្ទប់ |
| • គ្រួសារមិនមានប្រាក់គ្រប់គ្រាន់ | • នៅស្ងៀម |
| • ការងារច្រើនហួស | • បិទទ្វារខ្លាំងៗ |
| • បង្ខំឲ្យធ្វើនេះធ្វើនោះ | • រត់ចេញពីផ្ទះ |
| • ជេរប្រទេច ឬ ស្តីបន្ទោស | • កំណត់ហេតុ |
| • មិនអាចទទួលបានអ្វីដែលគេចង់បាន | • ស្រែកដាក់គេ |
| • សម្លុតគេឯង | • ចាប់ផ្តើមវាយតប់ |
| • អំពើហិង្សានៅក្នុងគ្រួសារ | • សេពគ្រឿងញៀន/ផឹកស្រា |
| • ខូចចិត្ត | • ឈប់ធ្វើកិច្ចការផ្ទះ |
| | • ដេកច្រើន |
| | • ធ្វើអត្តឃាត |
| | • ធ្វើទុក្ខទោសខ្លួនឯង |

# ១៧ មេរៀនទី១៧ ៖ ជាអ្នកជួញដូរមនុស្ស ឬមិនមែន?

**ចំណុចបំណង**

យុវជននឹងយល់ថា អ្នកជួញដូរធ្វើពុតជាមិត្តភក្តិដើម្បីបោកបញ្ឆោតអ្នកដទៃ។ យុវជននឹងចេះពិចារណា អំពីចរិកលក្ខណៈនៃទំនាក់ទំនង និងសិក្សាអំពីរបៀបធ្វើឲ្យមានសុវត្ថិភាពលើទំនាក់ទំនងខាងលើ។

**ពេលវេលា**

៧៥ នាទី

**សម្ភារៈ**

- ប៊ិចពណ៌ និងក្រដាសមួយសន្លឹកសម្រាប់យុវជនម្នាក់ៗ
- ថតចម្លងបីច្បាប់នូវ "IS ១៧ក៖ ជាអ្នកជួញដូរមនុស្ស ឬមិនមែន?" (យុវជនប្រើ IS នេះនៅក្នុងក្រុមមានគ្នាពី ១០-១៤ នាក់)

**សេចក្តីផ្តើម**

**ការស្វាគមន៍**

ស្វាគមន៍យុវជនដោយហៅឈ្មោះ។ ហុចបញ្ជីឈ្មោះតៗគ្នាដើម្បីចុះហត្ថលេខា។

**សកម្មភាពមុនចាប់ផ្តើម**

ឲ្យអ្នកសម្របសម្រួលជាយុវវ័យជ្រើសរើសសកម្មភាពចាប់ផ្តើមមុននៅក្នុងតារាង។

**ការរំឭកមេរៀន**

តើនរណាអាចចាំបានអំពីជំហានទាំងបីសម្រាប់ដោះស្រាយបញ្ហាអារម្មណ៍ពិបាកដែរ ឬទេ?
តើមាននរណាបានប្រើប្រាស់ជំហានទាំងនេះនៅក្នុងជីវិតប្រចាំថ្ងៃរបស់ខ្លួនដែរ ឬទេ?
តើជំហានទាំងនេះបានជួយដល់អ្នកដែរ ឬទេ?

## ការកំណត់អត្តសញ្ញាណអ្នកជួញដូរ

ពន្យល់ថា ម៉ោងសិក្សាថ្ងៃនេះ និយាយអំពីការសម្គាល់ចរិកលក្ខណៈនៃទំនាក់ទំនង និងរបៀបកំណត់អត្តសញ្ញាណថា តើនរណាជាអ្នកជួញដូរមនុស្សដែលធ្វើពុតជាមិត្តភក្តិយើង។
ពន្យល់ថា អ្នកធ្វើចំណាកស្រុកតែងតែជួបប្រទះបញ្ហានេះ។
ពន្យល់យុវជនថា ជនចំណាកស្រុកតែងតែធ្វើដំណើរទៅកាន់កន្លែងដែលគេមិនស្គាល់។ គេត្រូវការរាប់អានមិត្តភក្តិ ដើម្បីឲ្យគេអាចជជែកជាមួយអ្នកដទៃ និងអាចជួយដល់គេនៅក្នុងជីវិតបាន។ ប៉ុន្តែអ្នកជួញដូរវិញ គឺព្យាយាមបោកប្រាស់ អ្នកធ្វើចំណាកស្រុក ដោយការធ្វើពុតជាមិត្តភក្តិ។ ដូច្នេះ ៖

- តើជនចំណាកស្រុក កំណត់អត្តសញ្ញាណរបស់អ្នកជួញដូរ ដែលបន្លំជាមិត្តភក្តិដោយរបៀបណា?

វាមានសារៈសំខាន់ណាស់ដែលត្រូវនិយាយថាមិនមានចម្លើយត្រូវឥតខ្ចោះចំពោះសំណួរនេះទេ។ មិនមានមធ្យោបាយងាយស្រួល ក្នុងការកំណត់អត្តសញ្ញាណអ្នកជួញដូរមនុស្សនោះទេ។
ពន្យល់ថា នេះមានន័យថា នៅពេលណាដែលមានអ្នកណាសួរអ្នកឲ្យទៅរកកន្លែងថ្មី ធ្វើការងារថ្មី ជានិច្ចកាលអ្នកត្រូវគិតថា តើការងារនេះអាចមានគ្រោះថ្នាក់ដល់ខ្ញុំដូចម្តេចខ្លះ?

ពន្យល់ថា បើទោះបីជាមិនមានមធ្យោបាយដែលត្រូវតែតខ្ជោះដើម្បីកំណត់អត្តសញ្ញាណលើអ្នកជួញដូរមនុស្សក៏ដោយ។ ម៉ោងសិក្សានេះ គឺអំពីសញ្ញាប្រមានដែលគួរជួយដល់ជនចំណាកស្រុក នៅពេលដែលមានការសង្ស័យលើជនចម្លែកដែលខិតចូលជិតគេដែលផ្តល់ការជួយ និងរបៀបធ្វើតេស្តបុគ្គលនោះ។

## ការគូររូប

ចែកក្រដាស និងប៊ិច។

ឲ្យយុវជនគិតពីមិត្តម្នាក់។ ម្នាក់អាចជាមិត្តល្អបំផុតមកពីសហាគមន៍របស់គេនៅពេលដែលគេធំឡើងជាមួយគ្នា ឬជាមិត្តភក្តិក្នុងពេលបច្ចុប្បន្ន។ វាមិនអាចជាបុគ្គលម្នាក់ដែលគេទើបស្គាល់នោះទេ ប៉ុន្តែជាអ្នកដែលគេស្គាល់អស់រយៈពេលជាយូរយារណាស់មកហើយ និងមានការជឿជាក់។ ឲ្យពួកគេគូររូបភាពមួយអំពីមិត្តភក្តិរបស់គេ និងបង្ហាញជាពាក្យសម្តី ឬជារូបភាពថា ហេតុអ្វីបានជាគេចូលចិត្តមិត្តម្នាក់នេះ និងចរិកលក្ខណៈដែលធ្វើឲ្យមនុស្សម្នាក់នោះជាមិត្តដ៏ល្អ។

សួរពួកគេថា តើគេប្រើពេលប៉ុន្មានដើម្បីស្គាល់បុគ្គលម្នាក់នោះ។ ពន្យល់ថា យើងនឹងមើលលើរូបភាពទាំងអស់នេះម្តងទៀតនៅពេលចុងបញ្ចប់នៃម៉ោងសិក្សានេះ។

## អ្នកជួញដូរធ្វើពុតជា មិត្តភក្តិ

ពន្យល់ថា វាអាចជាការលំបាកក្នុងការកំណត់អត្តសញ្ញាណជនជួញដូរមនុស្សណាស់។ ផ្អែកលើរឿងរបស់ជនចំណាកស្រុកមួយចំនួន ពន្យល់នូវការរៀបរាប់អំពីសញ្ញាព្រមាន ដែលមនុស្សម្នាក់ព្យាយាមធ្វើជា “មិត្តភ័ក្តិ” របស់អ្នកអាចជាជនជួញដូរមនុស្ស។

### សញ្ញាព្រមាន

**ពេល ៖** អ្នកជួញដូរអាចបង្កើត “មិត្តភ័ក្តិ” បានភ្លាមៗ

ប្រាប់សិស្សថា អ្នកជួញដូរអាចនឹងព្យាយាមបង្កើតមិត្តភក្តិយ៉ាងរហ័សបំផុត។ ឧទាហរណ៍ថា គេប្រហែលជាជួបមនុស្សម្នាក់ដែលការពិតគេជាអ្នកជួញដូរមនុស្ស ជាលើកទីមួយនៅលើរថភ្លើង ហើយនៅពេលចុះពីរថភ្លើង អ្នកជួញដូរមនុស្សអាចនឹងឲ្យគេជឿជាក់លើខ្លួនបានដើម្បីតាមគេទៅធ្វើការងារមួយបាន។

ពន្យល់ថា អ្នកជួញដូរមនុស្សប្រហែលជាចង់ឲ្យពួកគេធ្វើសេចក្តីសម្រេចចិត្តភ្លាមៗ ពីព្រោះគេមិនចង់ឲ្យពួកគេមានពេលគិតអំពីអ្វីដែលគេកំពុងនិយាយ ឬជជែកជាមួយអ្នកដទៃអំពីបញ្ហានេះទេ។

ប្រាប់សិស្សឲ្យគិតអំពីមិត្តភក្តិរបស់គេ ៖ តើអ្នកនឹងទៅតាមគេទៅកន្លែងដែលអ្នកមិនធ្លាប់ទៅពីមុនបន្ទាប់ពីទើបបានស្គាល់គេប៉ុន្មានម៉ោងនោះដែរ ឬទេ?

**សំណួរ ៖** អ្នកជួញដូរអាចសួរសំណួរច្រើនពាក់ព័ន្ធនឹងរឿងផ្ទាល់ខ្លួន។

ប្រាប់យុវជនថា អ្នកជួញដូរ ប្រហែលជាចង់ដឹងអំពីរបៀបងាយស្រួលយ៉ាងណាក្នុងការជួញដូរគេហើយថា តើគេមានគ្រួសារដែលព្យាយាមស្វែងរកពួកគេដែរ ឬទេនៅពេលដែលគេបាត់ខ្លួននោះ។ ដើម្បីដឹងពីរឿងនេះ អ្នកជួញដូរអាចនឹងសួរសំណួរជាច្រើនអំពី តើគេរស់នៅកន្លែងណា ហើយថាតើនរណាខ្លះដែលគេស្គាល់នៅកន្លែងដែលគេកំពុងរស់នៅ។

ពន្យល់ថា អ្នកជួញដូរប្រហែលជាចង់ដឹងអំពីបុគ្គលនោះផងដែរ ដូច្នេះគេអាចធ្វើពុតជាចូលចិត្ត គេ។ អ្នកជួញដូរនឹងនិយាយថា គេក៏ក្រីក្រដែរ ហើយក៏មកពីខេត្តដូចគ្នាដែរដើម្បីឲ្យគេគិតថា គេមកពីប្រភពដូចគ្នា។

ប្រាប់យុវជនឲ្យគិតអំពីមិត្តភក្តិរបស់គេ ៖ តើគេបានសួរអ្នកនូវសំណួរជាច្រើនអំពីរឿងផ្ទាល់ខ្លួន ភ្លាមៗនៅពេលដែលគេបានជួបអ្នកដំបូងដែរ ឬទេ?

**ការកុហក ៖** ការកុហករបស់អ្នកជួញដូរ

ប្រាប់យុវជនថា អ្នកជួញដូរមនុស្សមិនអាចនិយាយពីការពិតបានទេ។ ប្រសិនបើគេនិយាយ ពិតនោះ គឺមិនមាននរណាម្នាក់ទទួលបានការងារនោះទេ។ ដូច្នេះគេត្រូវកុហក។ វាមានសារៈ សំខាន់ណាស់ដែលតវស្តាប់ គេដោយយកចិត្តទុកដាក់អំពីអ្វីដែលគេនិយាយ ប្រសិនបើគេ និយាយ ជាន់កែងខ្លួនឯង។

ប្រាប់យុវជនឲ្យគិតថា ៖ តើនេះខុសពីអ្វីដែលបុគ្គលនេះបានិយាយកាលពីមុនដែរ ឬទេ? តើនេះ ហាក់បីដូចជាពិតប្រាកដសម្រាប់ខ្ញុំដែរ ឬទេ? តើនេះស្តាប់ទៅហាក់បីដូចជាការងារពិតប្រាកដ ដែរ ឬទេ? តើបុគ្គលនេះកំពុងសុំខ្ញុំឲ្យធ្វើអ្វីម្យ៉ាងដែលអាចមានគ្រោះថ្នាក់ដែរ ឬទេ?

**ការសន្យា ៖** អ្នកជួញដូរសន្យាល្អពេកហួសពីការពិត។

ពន្យល់ថា អ្នកជួញដូរតែងតែចង់បញ្ឆោតគេឲ្យទៅតាមខ្លួន។ ដូច្នេះគេផ្តល់នូវអ្វីដែលល្អលើសពី ការពិត ឧទាហរណ៍ដូចជា ការងារដែលមានប្រាក់ខែខ្ពស់។ ក្នុងករណីថ្មីមួយ មានក្មេងស្រីពីរនាក់ ត្រូវបានជួញដូរដោយស្ត្រីម្នាក់ដែលផ្តល់ឲ្យពួកគេនូវការចំណាយសម្រាប់ការធ្វើដំណើរពេញមួ យថ្ងៃឆ្លងកាត់ព្រំដែន។

ប្រាប់យុវជនឲ្យគិតថា ៖ ហេតុអ្វីបានជាបុគ្គលនេះផ្តល់នូវអ្វីបែបនេះសម្រាប់ខ្ញុំ? ហេតុអ្វីបានជា ការងារដែលមានប្រាក់ខែខ្ពស់បែបនេះមិនត្រូវបានគេបើកចំហរ (ជាពិសេសប្រសិនបើខ្ញុំមាន កម្រិតវប្បធម៌)? ហេតុអ្វីបានជាជនមិនធ្លាប់ស្គាល់គ្នាហានចំណាយសោហ៊ុយធ្វើដំណើរពេញ មួយថ្ងៃឆ្លងកាត់ព្រំដែន?

**ការធ្វើដំណើរ ៖** អ្នកជួញដូរចង់ឲ្យអ្នកទៅតាមគេ

ពន្យល់ថា អ្នកជួញដូរប្រហែលជាចង់ឲ្យអ្នកទៅកន្លែងណាមួយជាមួយគេ។

ប្រាប់យុវជនឲ្យគិតថា ៖ ប្រសិនបើ ការងារនេះជាការងារពិតប្រាកដ ខ្ញុំគួរតែមានលទ្ធភាពធ្វើ ដំណើរទៅទីនោះដោយខ្លួនឯងបាន។ ប្រសិនបើនោះជាការពិតប្រាកដ ខ្ញុំគួរអាចទៅមើលទីតាំង នោះបានជាមួយក្រុមមនុស្សដទៃទៀត។

## ការពិភាក្សា

សូមឲ្យយុវជនគិតត្រឡប់ក្រោយវិញទៅមេរៀនអំពីទំនាក់ទំនងបែបហ្មត់ចត់និងឲ្យយុវជន ពន្យល់ឡើងវិញថា តើវាមានន័យដូចម្តេច?

ទំនាក់ទំនងបែបហ្មត់ចត់ មានន័យថា បុគ្គលម្នាក់និយាយស្តីក្នុងវិធីមួយដែលប្រព្រឹត្តលើអ្នកដទៃ ដោយការគោរព ហើយស្របពេលជាមួយគ្នានេះដែរ គឺគេមិនបដិសេធសិទ្ធិរបស់ខ្លួនទេ។

ឲ្យយុវជនគិតអំពីប្រយោគបែបហ្មត់ចត់ដែលគេអាចធ្វើបាន ប្រសិនបើគេយល់ឃើញថាខ្លួនគេមានការខ្វែងគំនិតជាមួយអ្នកដទៃដែលសួរសំណួរច្រើនហួសនិងលឿនខ្លាំងពេក។
ឧទាហរណ៍រួមមាន ៖

- "ខ្ញុំមានអារម្មណ៍មិនសូវស្រួលក្នុងការឆ្លើយសំណួរអំពីរឿងផ្ទាល់ខ្លួនទាំងនេះទេ។"
- "ទេ ខ្ញុំមិនស្គាល់អ្នកទេ។ ខ្ញុំមិនអាចទទួលយកការងារពីមនុស្សមិនធ្លាប់ស្គាល់ទេ។"
- "តើប្រាក់ប៉ុន្មានដែរ? តើបើកឲ្យពេលណា? ហើយដោយរបៀបណា?"

## សំណួរខ្លីធ្វើតេស្តមិត្តភក្តិ

ពន្យល់ថា មានមធ្យោបាយជាច្រើនដើម្បីការពារខ្លួនអ្នកដោយការធ្វើតេស្តបុគ្គលដែលអ្នកទើបបានជួប។ ការធ្វើតេស្តទាំងនេះនឹងមិនមែនជាបញ្ហាសម្រាប់នរណាម្នាក់ដែលចង់ធ្វើជាមិត្តភក្តិរបស់អ្នកនោះទេ ពីព្រោះគេនឹងគិតពីវាថា ជាផ្នែកមួយនៃទំនាក់ទំនងពិតប្រាកដ។ ប៉ុន្តែប្រសិនបើ "មិត្តភក្តិ" ជាអ្នកជួញដូរ" នោះ ការធ្វើតេស្តទាំងនេះ នឹងជួយឲ្យអ្នកដឹងច្បាស់អំពីអ្វីដែលខុសប្រក្រតីជាមួយនឹងទំនាក់ទំនងបែបនេះ។

### ការពន្យាពេល

ពន្យល់ថា ប្រសិនបើនរណាម្នាក់ត្រូវផ្តល់ការងារមានប្រាក់ខែខ្ពស់ គេអាចព្យាយាមពន្យាពេល។ គេអាចសុំលេខទូរស័ព្ទរបស់បុគ្គលនោះ និងសួរនាំអំពីព័ត៌មានលម្អិតពីការងារនោះ។ ការធ្វើបែបនេះ នឹងជួយដល់គេឲ្យដឹងច្បាស់អំពីទីកន្លែងដែលការងារនោះស្ថិតនោះ និងក្រុមហ៊ុន។ វាក៏នឹងទុកពេលឲ្យពួកគេទូរស័ព្ទទៅកាន់ឪពុកម្តាយរបស់គេ ដើម្បីប្រាប់ពីកន្លែងដែល គេនឹងទៅផងដែរ។ ប្រសិនបើបុគ្គលនោះមិនអាចពន្យាពេលឲ្យបានទេនោះ វាគឺជាសញ្ញាព្រមានដែលប្រាប់ថា គេនោះអាចជាអ្នកជួញដូរម្នាក់។

### សួរសំណួរទៅខ្លួនឯង

ពន្យល់ពីសារៈសំខាន់នៃការសួរសំណួរ។ គេអាចសួរសំណួរអំពីថៅកែ កិច្ចសន្យា និងទីក្រុងដែលជាទីកន្លែងការងារស្ថិតនៅ។ អ្នកដែលបង្ហាញពីការងារដែលមានសុវត្ថិភាពនឹងមិនមានការភ័យខ្លាចប្រាប់គេអំពីអ្វីដែលគេដឹងនោះទេ។

សួរសំណួរអំពីជីវិតរបស់ "មិត្តភក្តិ" នោះ ដូចជាឈ្មោះសាលារៀនរបស់គេ និងឈ្មោះសមាជិកគ្រួសាររបស់គេ។ ពន្យល់ពីសារៈសំខាន់នៃការចងចាំចម្លើយ និងការសួរសំណួរដដែល នៅពេលក្រោយដែលជួបគ្នាដើម្បីធ្វើតេស្តថា តើគេនៅចង់ចាំដែរ ឬទេ។ បើជាមិត្តពិតគេនឹងចងចាំអ្វីដែលគេបាននិយាយ ពីព្រោះវាជាការពិត។ អ្នកជួញដូរ ប្រហែលជាមិនអាចទេ។

ពន្យល់ថា ប្រសិនបើ "មិត្តភក្តិ" និយាយខុសគ្នាពីអ្វីដែលគេបាននិយាយពីមុននោះ ឬស្រែកគំហកដាក់អ្នកដោយសារអ្នកសួរសំណួរនោះ វាគឺជាសញ្ញាព្រមានដែលប្រាប់ថា គេនោះអាចជាអ្នកជួញដូរ។

### ធ្វើដំណើរទៅកន្លែងធ្វើការតាមមធ្យោបាយសាធារណៈ

ពន្យល់ថា វាជាការល្អដែលត្រូវរៀបចំការធ្វើដំណើរទៅកន្លែងការងារតាមមធ្យោបាយធ្វើដំណើរសាធារណៈ ពីព្រោះវាមានសុវត្ថិភាពជាងការធ្វើដំណើរតាមរថយន្តឯកជនតូចជាមួយ

"មិត្តភ័ក្តិ" នោះ។ ប្រសិនបើគេធ្វើដំណើរជាមួយ "មិត្តភក្តិ" របស់គេនោះ វាអាចជា ការពិបាកក្នុងការចាកចេញ និងទៅផ្ទះវិញប្រសិនបើការងារនោះមិនល្អ ។ ប្រសិនបើគេធ្វើដំណើរតាមមធ្យោបាយធ្វើដំណើរសាធារណៈ គេអាចនាំអ្នកដែលគេស្គាល់ធ្វើដំណើរទៅជាមួយ។ ប្រសិនបើបើទីតាំងមើលទៅមានគ្រោះថ្នាក់ ឬនៅដាច់ឆ្ងាយពីគេនៅពេលដែលគេទៅដល់នោះ រំឭកដល់គេគេកុំឲ្យចាកចេញពីរថយន្តក្រុងសាធារណៈឲ្យសោះ។

**ត្រូវស្គាល់ "មិត្តភក្តិ" សិនមុនពេលអ្នកទៅកន្លែងផ្សេងជាមួយគេ**

ពន្យល់ថាវាត្រូវការពេលវេលាដើម្បីស្គាល់មិត្តភក្តិពិតប្រាកដ។ នៅពេលដែលជនចំណាកស្រុកជួបអ្នកដទៃ គេគួរចំណាយពេលបន្តិចដើម្បីស្គាល់គេមុនពេលគេជឿជាក់លើគេ។ សិស្សគួរព្យាយាម ៖

- គ្រួសាររបស់ "មិត្តភក្តិ" នោះ។ អ្នកជួញដូរប្រហែលជាមិនចង់និយាយពីគ្រួសាររបស់គេទេ ឬ អាចនឹងនិយាយខុសពីរឿងមុន។
- ណែនាំបុគ្គលនោះឲ្យមិត្តរបស់អ្នកស្គាល់គ្នា (ឬគ្រួសារ ប្រសិនបើគេរស់នៅជិតខាង)។ ប្រសិនបើ "មិត្តភក្តិ" មិនចង់ជួបជាមួយមិត្តផ្សេងទៀតរបស់អ្នកនេះគឺជាសញ្ញាព្រមានមួយ។ អ្នកជួញដូរប្រហែលជាមិនចង់ជួបមនុស្សច្រើននាក់ទេ។
- ប្រាប់បុគ្គលនោះថា អ្នកតែងតែទូរស័ព្ទទៅគ្រួសាររបស់អ្នកដើម្បីប្រាប់ពីជីវិតរស់នៅរបស់អ្នក និងថាអ្នកបានប្រាប់គ្រួសាររបស់អ្នក អំពីព័ត៌មានលម្អិត "មិត្តភក្តិ" ថ្មីរបស់អ្នករួចហើយ។ មិត្តភក្តិពិតប្រាកដច្បាស់ជាមានការរីករាយហើយដែលគេរំឭកពីខ្លួន ប៉ុន្តែអ្នកជួញដូរអាចនឹងរងការភិតភ័យ។
- ពិភាក្សាពីបុគ្គលនោះជាមួយអ្នកផ្សេងទៀត។ សួរអ្នកដទៃដែលធ្លាប់បានជួប ឬដឹងរឿងខ្លះអំពីបុគ្គលនោះ។ ប្រសិនបើមិនមាននរណាម្នាក់ធ្លាប់ស្គាល់ ឬដឹងព័ត៌មានល្អអ្វីមួយអំពី "មិត្តភក្តិ" នេះគឺជាសញ្ញាព្រមានមួយ។ មិត្តភក្តិពិតច្បាស់ជាស្គាល់មនុស្សនៅក្នុងសហគមន៍ ប៉ុន្តែអ្នកជួញដូរអាចនឹងមិនស្គាល់ទេ។

**ជួបគ្នានៅទីសាធារណៈ**

ប្រាប់យុវជនថា ប្រសិនបើគេជួប "មិត្តភក្តិ" ជួបនៅកន្លែងសាធារណៈដ៏មមារញឹកមួយដូច្នេះ មានមនុស្សនៅជុំវិញអ្នកប្រសិនបើមានអ្វីមិនប្រក្រតីកើតមានឡើង។ ប្រសិនបើគេ មានអារម្មណ៍ភ័យខ្លាច ឬភិតភ័យ គេអាចស្រែកឮៗឲ្យគេជួយបាន។ មិត្តភក្តិពិតប្រាកដ នឹងមានភាពរីករាយក្នុងការជួបគ្នានៅទីសាធារណៈ ប៉ុន្តែអ្នកជួញដូរមនុស្ស ប្រហែលមិនបែបនេះទេ។

ពន្យល់ថា នៅក្នុងសម័យទំនើបនេះ គេមិនគួរជឿអ្នកដទៃគ្រប់ពេលវេលានោះទេ។ ប្រសិនបើមាននរណាម្នាក់សុំជួបគេ ចង់ធ្វើដំណើរជាមួយ ឬទៅធ្វើការងារមួយ ជាការសំខាន់ គឺត្រូវមានការសង្ស័យ និងសួរខ្លួនឯងថា "តើរឿងបែបនេះអាចមានគ្រោះថ្នាក់ដល់ខ្ញុំដែរ ឬទេ?"

**សំណួរខ្លីអំពីអ្នកជួញដូរមនុស្ស**

បែងចែកយុវជនជាក្រុមដែលមានគ្នាពី ១០-១៤ នាក់។

សុំឲ្យយុវជនពីរនាក់ពីក្រុមនីមួយៗមកធ្វើជាអ្នកស្ម័គ្រចិត្តដើម្បីសម្តែងរឿង។

ឲ្យអ្នកសម្តែងម្នាក់នូវរឿងទី១ និងអ្នកសម្តែងម្នាក់ទៀតនូវរឿងទី ២ (ពី "IS ១៧ក ៖ អ្នកជួញដូរ

មនុស្ស ឬមិនមែន?")។ កុំឲ្យយុវជនផ្សេងទៀតឃើញរឿងទាំងពីរនោះឲ្យសោះ។
ពេលនេះ ឲ្យយុវជនអង្គុយជារង្វង់។ ឲ្យយុវជនអានរឿងដោយយកចិត្តទុកដាក់ និងឆ្លើយសំណួរ ធ្វើដូចជាគេជាមនុស្សនៅក្នុងសាច់រឿង។
ពន្យល់ទៅយុវជនថា ម្នាក់ក្នុងចំណោមអ្នកទាំងនេះ នឹងដើរតួជាអ្នកជួញដូរ ហើយម្នាក់ទៀត មិនមែនជាអ្នកជួញដូរទេ។ គេបានជួបមនុស្សទាំងពីរនាក់នេះនៅសួនសាធារណៈមួយ ហើយ គេត្រូវទស្សន៍ទាយថា តើមួយណាជាអ្នកជួញដូរមនុស្ស។
សមាជិកក្រុមនីមួយៗអាចសួរទៅតួអង្គទាំងពីរបានម្នាក់មួយសំណួរ។ តួអង្គនឹងឆ្លើយសំណួរ ទៅតាមប៉ារ៉ូល។ ដើរជុំវិញរង្វង់រហូតទាល់តែសមាជិកក្រុមម្នាក់ៗដែលមានសំណួរ បានសួរ សំណួរគ្រប់គ្នា។ (ប្រសិនបើនៅតែមិនច្បាស់ថា នរណាជាអ្នកជួញដូរបន្ទាប់ពីសមាជិកក្រុម នីមួយៗបានសួរសំណួរអស់ហើយនោះ អ្នកអាចឲ្យគេសួរសំណួរបន្ថែមរហូតទាល់តែច្បាស់លាស់)។
ជាចុងក្រោយ ឲ្យយុវជនទស្សន៍ទាយថា នរណាជាអ្នកជួញដូរ។

## ការពិភាក្សា

ឲ្យយុវជនទាំងអស់គ្នាប្រមូលផ្តុំគ្នាម្តងទៀត។ឲ្យពួកគេគិតអំពីសំណួរខ្លី។

- តើអ្នកអាចកំណត់អត្តសញ្ញាណអ្នកជួញដូរមនុស្សបានយ៉ាងដូចម្តេច?

ពេលនេះ ឲ្យសិស្សយកចេញនូវរូបភាពអំពីមិត្តភក្តិពិតប្រាកដដែលគេបានគូរកាលពីពេលចាប់ ផ្តើមមេរៀននេះ។ សួរទៅគេថា ៖

- តើអ្នកបានស្គាល់មិត្តភក្តិនៅក្នុងរូបភាពរបស់អ្នករយៈពេលប៉ុន្មានហើយ?
- តើអ្នកដឹងថាមិត្តភក្តិរបស់អ្នកនេះរស់នៅទីណា ស្គាល់គ្រួសាររបស់គេនិងរបៀបដែលគេ ចំណាយពេលប្រចាំថ្ងៃដែរ ឬទេ?
- តើអ្នកមានស្គាល់អ្នកដទៃដែលស្គាល់មិត្តភក្តិរបស់អ្នកនេះ ដូចជាមិត្តរួមថ្នាក់ឬមនុស្សនៅ ក្នុងសហគមន៍ដែរ ឬទេ?
- តើមិត្តភក្តិរបស់អ្នកម្នាក់នេះបានសួរសំណួរអ្នកជាច្រើន នៅពេលដែលគេជួបអ្នកដំបូង ដែរឬទេ?
- តើមិត្តភក្តិបានឲ្យប្រាក់អ្នកនៅពេលដែលជួបអ្នកដំបូងដែរ ឬទេ?

  បន្ទាប់មកឲ្យគេផ្តល់នូវឧទាហរណ៍អំពីភាពខុសគ្នារវាងមិត្តភក្តិនេះ និងអ្នកជួញដូរមនុស្ស ដែលធ្វើពុតជាមិត្តរបស់អ្នក។

### ការព្រមាន

ពន្យល់ថា មធ្យោបាយមួយចំនួនដែលអ្នកជួញដូរព្យាយាមបញ្ឆោតអ្នកដទៃ និងមធ្យោបាយ មួយចំនួនសម្រាប់ធ្វើតេស្តទំនាក់ទំនងត្រូវពិភាក្សារួចហើយ។ ប៉ុន្តែត្រូវនិយាយថា មនុស្សម្នាក់ អាចឆ្លងកាត់ការធ្វើតេស្តនេះរួច ហើយនៅតែអាចជាអ្នកជួញដូរម្នាក់ផងដែរ។
ឧទាហរណ៍ថា អ្នកខ្លះត្រូវបានជួញដូរដោយសមាជិកគ្រួសារ ឬដោយអ្នកជិតខាងដែលគេបាន ស្គាល់រយៈពេលជាច្រើនឆ្នាំមកហើយ។
ពន្យល់ប្រាប់ថា អ្នកជួញដូរខ្លះអាចធ្វើពុតជាមិត្តភក្តិរបស់គេ ឬអាចមិត្តប្រុស ឬមិត្តស្រីរបស់គេ

រយៈពេលយូរផងដែរមុនពេលគេនិយាយប្រាប់អំពីការងារ។
មុនពេលអ្នកទទួលយកការផ្តល់ឲ្យអ្វីមួយ ឬធ្វើដំណើរទៅកន្លែងណាមួយ ត្រូវគិតថា
"តើការធ្វើបែបនេះអាចមានគ្រោះថ្នាក់ដល់ខ្ញុំដែរ ឬទេ?"

## កំណត់ហេតុ

• ឲ្យយុវជនសរសេរ ឬគូរក្នុងកំណត់ហេតុរបស់គេរយៈពេល ១០ នាទី អំពីប្រធានបទអ្វីដែលគេចង់។

**សង្ខេបមេរៀន**

- មិនមានមធ្យោបាយ ដែលត្រូវឥតខ្ចោះដើម្បីកំណត់អត្តសញ្ញាណលើអ្នកជួញដូរមនុស្សនោះទេ។ ជានិច្ចកាល អ្នកត្រូវពិចារណាពីរបៀបទទួលយកការផ្តល់ឲ្យនូវការធ្វើដំណើរជាមួយនរណាម្នាក់ ឬធ្វើការងារអ្វីមួយអាចនឹងនាំឲ្យអ្នកធ្លាក់ចូលក្នុងគ្រោះថ្នាក់។
- ចងចាំថា អ្នកជួញដូរអាចជាមិត្តភក្តិ ជាសមាជិកគ្រួសារ ឬអ្នកជិតខាងរបស់អ្នកផងដែរ។
- មានសញ្ញាព្រមានមួយចំនួនដែលគួរឲ្យអ្នកសង្ស័យ។៖
    - អ្នកជួញដូរអាចបង្កើតមិត្តភក្តិបានភ្លាមៗ។
    - អ្នកជួញដូរសួរសំណួរជាច្រើនអំពីរឿងផ្ទាល់ខ្លួន។
    - អ្នកជួញដូរនិយាយកុហក់។
    - អ្នកជួញដូរសន្យាល្អហួសពីការពិត។
    - អ្នកជួញដូរអាចនឹងចង់ឲ្យអ្នកទៅជាមួយគេភ្លាមៗ
- អ្នកអាចធ្វើតេស្តបុគ្គលម្នាក់ដោយការធ្វើដូចខាងក្រោម ៖
    - ពន្យារពេល។
    - សួរសំណួរផ្សេងៗ។
    - ធ្វើដំណើរទៅកន្លែងការងារតាមមធ្យោបាយធ្វើដំណើរសាធារណៈ។
    - ស្គាល់គេឲ្យបានច្បាស់មុននឹងអ្នកទៅកន្លែងណាមួយជាមួយគេ។
    - ជួបគ្នានៅទីសាធារណៈមមារញឹកមួយ។
- ជានិច្ចកាលត្រូវគិតពីសុវត្ថិភាពមុនទំនាក់ទំនង។ ប្រសិនបើមាននរណាម្នាក់ស្នើសុំជួប ធ្វើដំណើរ ឬ ធ្វើការងារថ្មីមួយ ត្រូវសួរខ្លួនឯងជានិច្ចថា "តើការធ្វើបែបនេះអាចមានគ្រោះថ្នាក់ដល់ខ្ញុំដែរ ឬទេ?"

# IS ១៧ក ÷ តើជាអ្នកជួញដូរ ឬមិនមែន?

១៧

## រឿងទី ១

**អ្នកគឺជាអ្នកជួញដូរម្នាក់។**

អ្នកនឹងធ្វើពុតថាអ្នកមកពីខេត្តដូចគ្នានឹងមនុស្សដែលសួរសំណួរទៅអ្នកអំពីប្រភពដែលអ្នកមកពី។ អ្នកនឹងធ្វើជានិយាយថា អ្នកមានបងប្អូនប្រុសពីរនាក់ និងប្អូនស្រីម្នាក់។

អ្នករស់ក្នុងទីក្រុងធំមួយ។ អ្នកតែងតែបង្កើតមិត្តភក្តិជាមួយមនុស្សក្មេងៗនៅតាមសួនច្បារ។ អ្នកនាំគេតាមរថយន្តមួយទៅកាន់រោងចក្រនៅក្រៅពីទីក្រុង។

រោងចក្រនោះឲ្យប្រាក់ទៅអ្នកឲ្យអ្នកធ្វើបែបនេះ។ អ្នកមិនដឹងច្បាស់ទេថា តើការងារអ្វីដែល កម្មករធ្វើនៅក្នុងរោងចក្រនោះទេ។ អ្នកគិតថា ការងារដែលត្រូវធ្វើគឺការងារត្រឹខកំប៉ុង ប៉ុន្តែអ្នកមិនដែដែលចូលទៅក្នុងរោងចក្រនោះទេ។

អ្នកដឹងថា វាជាការមិនល្អទេ ហើយកម្មករមិនត្រូវបានអនុញ្ញាតិឲ្យចេញក្រៅទេ។

អ្នកបានប្រាប់ជនចំណាកស្រុកថា ប្អូនស្រីរបស់អ្នកក៏ធ្វើកាងារនៅក្នុងរោងចក្រមួយនោះដែរ។

អ្នកមិនចង់ជួបជាមួយមិត្តណាម្នាក់របស់ជនចំណាកស្រុកទេ ពីព្រោះអ្នកមិនចង់ឲ្យគេចងចាំពីរូបរាងរបស់អ្នក។

អ្នកចង់ជួបគ្នានៅកន្លែងស្ងាត់ពីព្រោះអ្នកមិនចង់ឲ្យមានមនុស្សច្រើនឃើញអ្នក។

អ្នកស្គាល់លេខទូរស័ព្ទរបស់រោងចក្រនោះ។

អ្នកមិនចង់ប្រាប់អ្នកដទៃអំពីឈ្មោះ និងទីតាំងរោងចក្រនោះទេ។

អ្នកចង់នាំជនចំណាកស្រុកទៅទីនោះតាមរថយន្ត ដូចនេះ គេពុំអាចរត់គេចបាន។

## រឿងទី ២

អ្នកគឺជាមិត្តភក្តិម្នាក់។

អ្នកជាមនុស្សចំណូលថ្មីនៅក្នុងទីក្រុងនេះ ហើយអ្នកចង់រាប់អានមិត្តភក្តិថ្មីៗ។

អ្នកមិនមានប្រាក់ច្រើនទេ។

អ្នកដឹងមានបឹងមួយកន្លែងនៅក្បែរនោះ ជាទីដែលមានការកំសាន្តសម្រាប់ដើរលេង និងដេកគ្នាបាន។

អ្នកធ្វើការនៅក្នុងរោងចក្រកាត់ដេរមួយកន្លែង ហើយអ្នករីករាយដែលមានមិត្តភក្តិថ្មីធ្វើការជាមួយអ្នកនៅទីនោះ។ អ្នករីករាយក្នុងការឲ្យលេខទូរស័ព្ទអ្នកដែលទទួលខុសត្រូវការងារជ្រើសរើសបុគ្គលិកនៅរោងចក្រនោះ។

អ្នករីករាយក្នុងការណែនាំមិត្តថ្មីរបស់អ្នកទៅកាន់អ្នកដទៃទៀតដែលអ្នកស្គាល់។

# ១៨ មេរៀនទី១៨៖ សុវត្ថិភាពក្នុងការប្រើអ៊ិនធឺណិត

សម្រាប់អ្នកសម្របសម្រួល ៖ ដកមេរៀននេះចេញប្រសិនបើអ្នកចូលរួមមិនមានអ៊ិនធឺណិតប្រើប្រាស់។

## ចំណុចបំណង

អ្នកចូលរួមនឹងដឹងពីគ្រោះថ្នាក់នៃការប្រើប្រាស់អ៊ិនធឺណិត ហើយនឹងដឹងពីវិធីដើម្បីគេចផុតពីគ្រោះថ្នាក់ទាំងនេះដើម្បីការពារខ្លួនគេ។

## ពេលវេលា

៧៥ នាទី

## សម្ភារៈ

- ប័ណ្ណនិយាយអំពី គ្រោះថ្នាក់តាមអ៊ិនធឺណិត (ប័ណ្ណមួយសំណុំ ដែលធ្វើឡើងដោយការកាត់ប័ណ្ណចេញនៅលើ "ឯទ ១៨ក៖ ប័ណ្ណនិយាយពីគ្រោះថ្នាក់តាមអ៊ិនធឺណិត" ចេញជា ៦ ប័ណ្ណ។ ម្ខាងនៃប័ណ្ណមានពាក្យថា "គ្រោះថ្នាក់"នៅខាង ក និងម្ខាងទៀតមានឃ្លាថា "របៀបការពារខ្លួនអ្នក" នៅខាងខ)។
- ចង់មួយ
- ចតចម្លង "ឯទ ១៨ខ ៖ រឿងរបស់ មីង" សម្រាប់អ្នកចូលរួមគ្រប់គ្នា ក្រដាសផ្ទាំងធំ

## សេចក្ដីផ្ដើម

### ការស្វាគមន៍

ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះ។

### សកម្មភាពមុនចាប់ផ្ដើម

ជ្រើសរើសល្បែងថាមពលនៅក្នុងតារាង។

### ការរំឭកមេរៀន

តើនរណាអាចចាំបានពីវិធីក្នុងការកំណត់អត្តសញ្ញាណថា តើជនណាជាអ្នកជួញដូរមនុស្សមែនដែរឬទេ?

## ការពិភាក្សា

ការប្រើប្រាស់អ៊ិនធឺណិតអាចជារឿងល្អ។វាអាចជួយឲ្យមនុស្សរក្សាទំនាក់ទំនងគ្នាបានល្អដឹងបានច្រើនអំពីពិភពលោក និងភ្ជាប់ទំនាក់ទំនងជាមួយមិត្តភក្ដិបាន។ ក្នុង កម្រងឯកសារនេះ អ៊ិនធឺណិត នឹងត្រូវបានប្រើប្រាស់ដើម្បីស្រាវជ្រាវអំពីការប្រឆាំងនឹងការជួញដូរមនុស្ស និងជួយកំណត់សម្គាល់ពីព្រឹត្តការណ៍នៅក្នុងសហគមន៍។ប៉ុន្តែអ៊ិនធឺណិតក៏អាចមានគ្រោះថ្នាក់សម្រាប់មនុស្សផងដែរ ហើយក្នុងមេរៀននេះនិយាយអំពីរបៀបការពារខ្លួនអ្នកពីគ្រោះថ្នាក់តាមបណ្ដាញអ៊ិនធឺណិត។

ឲ្យក្រុមទះដៃ នៅពេលគេកំពុងហុចចង់តៗគ្នានេះ។ នៅពេលដែលអ្នកនិយាយថា "ឈប់" ត្រូវឈប់ហុចចង់នោះទៀត ហើយអ្នកដែលកំពុងកាន់ចងក្នុងពេលនោះ ត្រូវលូកយកប័ណ្ណមួយ។ អ្នកចូលរួមនេះ ត្រូវអានឲ្យឮៗនៅផ្នែកខាង ក ជាមុនសិន ដែលរៀបរាប់អំពីគ្រោះថ្នាក់ ហើយបន្ទាប់មកអានផ្នែកខាង ខ ដែលរៀបរាប់អំពីរបៀបការពារខ្លួនអ្នក។

នៅពេលដែលគេបានអានប័ណ្ណៗ សួរថាតើមាននរណានៅក្នុងក្រុមយល់ដែរ ឬទេ។ ពន្យល់បន្ថែមប្រសិនបើចាំបាច់។

## ការណែនាំអំពីការប្រុងប្រយ័ត្នជាមុន

នៅពេលដែលប័ណ្ណទាំងអស់ត្រូវបានអានរួច ពន្យល់ថា ការប្រុងប្រយ័ត្នជាមុនដូចខាងក្រោមនេះ អាចការពារយុវវ័យបាន។ (សរសេរការប្រុងប្រយ័ត្នមុនទាំងនោះនៅលើក្រដាសផ្ទាំងធំពេលអ្នកកំពុងនិយាយ)។

- កុំចែកចាយព័ត៌មានផ្ទាល់ខ្លួនតាមបណ្តាញអ៊ិនធឺណិត។
- ប្រសិនបើបណ្តាញនានាដូចជា Yahoo ឬ Twitter សួររកព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកនៅក្នុងទំព័ររបស់អ្នកនោះ ត្រូវធ្វើឲ្យមានលក្ខណៈទូទៅបំផុតតាមដែលអាចធ្វើបាន។ រៀបរាប់ពីទីក្រុងដែលអ្នករស់នៅនោះ មិនមែនអំពីអាសយដ្ឋានផ្លូវទេ។ មិនត្រូវផ្តល់នូវអាសយដ្ឋានរបស់អ្នក លេខទូរស័ព្ទរបស់អ្នក ឈ្មោះ ឬអាសយដ្ឋានសាលារៀនបច្ចុប្បន្ន ឬពីមុនរបស់អ្នក ។ មិនត្រូវចែកចាយអាសយដ្ឋាន អ៊ីម៉ែលរបស់អ្នកនៅលើទំព័ររបស់អ្នកឡើយ។ ដកមុខងារ “ប្រាប់ពីទីតាំងភូមិសាស្ត្រ” ចេញពីហ្វេសប៊ុក និងធ្វើតាមចេញ ពីព្រោះមុខងារនេះប្រាប់អ្នកអ្នកដទៃអំពីទីតាំងដែលអ្នកស្ថិតនៅ។
- គ្រប់គ្រងការកំនត់សិទ្ធិឯកជនភាព (Privacy Setting)។ បណ្តាញមួយចំនួន ដូចជា ហ្វេសប៊ុកជាដើម មានការកំណត់សិទ្ធិឯកជនភាព។ ជានិច្ចកាល ត្រូវបើកមើលការកំណត់ ទាំងនេះហើយជ្រើសរើស យកការកំណត់ដែលអនុញ្ញាតិឲ្យតែមិត្តភក្តិរបស់អ្នកប៉ុណ្ណោះដែល ដឹងពីព័ត៌មានរបស់អ្នក។ មិនត្រូវឲ្យមហាជនទូទៅដឹងពីព័ត៌មានរបស់អ្នកទេ។
- មិនត្រូវចែកចាយពាក្យសម្ងាត់ឡើយ។ មិនត្រូវចែកចាយពាក្យសម្ងាត់របស់អ្នក ទោះបីជាមិត្តល្អបំផុត មិត្តប្រុស ឬមិត្តស្រីរបស់អ្នកក៏ដោយ។ មិត្តប្រុសរបស់អ្នក អាចថ្ងៃក្រោយក្លាយជាអតីតមិត្តប្រុសក៏ថាបាន។ គេអាចប្រើពាក្យសម្ងាត់របស់អ្នកដើម្បីចូលទៅក្នុងទំព័រហ្វេសប៊ុករបស់អ្នក ដោយបន្លំថា គេគឺជាអ្នក ហើយសរសេរអ្វីដែលអាចធ្វើឲ្យមាន ទុក្ខទោស ឬគួរឲ្យអាម៉ាស់។ មិត្តស្រីរបស់អ្នក អាចថ្ងៃក្រោយក្លាយជាអតីតមិត្តស្រី ហើយធ្វើដូចគ្នា បែបនេះ។
- មិនត្រូវចូលរួមក្នុងបន្ទប់ជជែក (Chat Room) ឡើយ។ មនុស្សនៅក្នុងបន្ទប់ជជែកកំសាន្តគឺជាមនុស្សដែលមិនធ្លាប់ស្គាល់ ហើយអាចជាអ្នកស៊ើបការណ៍ ឬជាចោរ។ ជជែកកំសាន្តតែជាមួយមនុស្សដែលអ្នកស្គាល់ច្បាស់បានហើយ។
- ត្រូវមានការ សង្ស័យជានិច្ចជាមួយនឹងការផ្តល់ការងារឲ្យធ្វើតាមបណ្តាញអិនធឺណិត។ មនុស្សនិយាយកុហក់ដើម្បីបោកបញ្ឆោតអ្នកឲ្យទៅធ្វើការងារដែលគ្រោះថ្នាក់ដោយប្រើប្រាស់បណ្តាញអ៊ិនធឺណិត។
- ប្រសិនបើអ្នកគិតថា អ្នកកំពុងស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់នៅតាមបណ្តាញអ៊ិនធឺណិតនោះ ត្រូវបិទកុំព្យូទ័ររបស់អ្នកភ្លាមៗ ហើយប្រាប់ឪពុកម្តាយអ្នក និងអ្នកសម្របសម្រួលក្លិបយុវវ័យ។ ប្រសិនបើអ្នកមានទំនាក់ទំនងជាមួយនរណាម្នាក់តាមបណ្តាញអ៊ិនធឺណិត ដែលកំពុង នាំឲ្យអ្នកធ្វើការប្រថុយ ឬបានធ្វើឲ្យអ្នកមានអារម្មណ៍មិនស្រួលនោះ ឬ ប្រសិនបើ

មាន នរណាម្នាក់នៅ អ្នកបានជួបតាមបណ្តាញអ៊ិនធឺណិតសុំជួបមុខអ្នកផ្ទាល់នោះ ចូរប្រាប់ឪពុកម្តាយអ្នក និងអ្នកសម្របសម្រួលក្លឹបយុវវ័យ។

## ការធ្វើការជាក្រុម

ចែក " IS ១៨ខ៖ រឿងរបស់ មីង"។

ឲ្យអ្នកចូលរួមបែងចែកជាក្រុមមានគ្នាពី ៤-៨ នាក់ អានរឿង ហើយបន្ទាប់មកសរសេរពីជំហាន ដែល មីង គួរអនុវត្តដើម្បីការពារខ្លួននាង។

នៅពេលដែលគេបានបញ្ចប់ ឲ្យក្រុមចែករំលែកចម្លើយរបស់គេ ប្រសិនបើនៅសល់ម៉ោង។

សំណួរវាស់ស្ទង់ចំណេះដឹងជាមួយដៃគូរ

ចុងក្រោយ ឲ្យសិស្សបែងចែកជាក្រុមមានគ្នាពីរនាក់។ ឲ្យក្រុមនីមួយៗសួរសំណួរឃ្លីសគ្នាទៅវិញទៅមក ដើម្បីពិនិត្យមើលថា តើគេអាចចងចាំពីការប្រុងប្រយ័ត្នមុនដើម្បីការពារខ្លួនអ្នកតាមបណ្តាញអ៊ិនធឺណិតដែរ ឬទេ។

### សង្ខេបមេរៀន

- មិនត្រូវចែកចាយព័ត៌មានផ្ទាល់ខ្លួន (ដូចជា ទីកន្លែង សាលារៀន លេខទូរស័ព្ទ និងថ្ងៃខែ ឆ្នាំកំណើតរបស់អ្នក) តាមបណ្តាញអ៊ិនធឺណិតឡើយ។
- មិនត្រូវទទួលយកមនុស្សមិនស្គាល់គ្នាមកធ្វើជាមិត្តភក្តិនៅលើបណ្តាញសង្គម ដូចជា ហ្វេសប៊ុក ឬធ្វីតធឺឡើយ។
- កំណត់ការគ្រប់គ្រង់និងសិទ្ធិឯកជនភាពរបស់អ្នកសម្រាប់ "មិត្តភក្តិ" របស់អ្នកប៉ុណ្ណោះនៅលើបណ្តាញសង្គមដូចជា ហ្វេសប៊ុកជាដើម។
- មិនត្រូវបើកមើលឯកសារភ្ជាប់ដែលគេផ្ញើមកឡើយ ប្រសិនបើអ្នកមិនដឹងថា ជាអ្វីឬនរណាជាអ្នកផ្ញើនោះ។
- មិនត្រូវជួបជាមួយនរណាម្នាក់ផ្ទាល់ដែលអ្នកបានជួបតាមបណ្តាញអ៊ិនធឺណិតឡើយ។
- ប្រសិនបើអ្នកជួបជាមួយនរណាម្នាក់ដែលអ្នកធ្លាប់ជួបតាមបណ្តាញអ៊ីនធឺណិត ត្រូវទៅជាមួយមិត្តភក្តិនៅកន្លែងទីសាធារណៈនៅពេលថ្ងៃ។
- មិនត្រូវប្រាប់នរណាម្នាក់ពីពាក្យសម្ងាត់របស់អ្នកឡើយ។
- មិនត្រូវចែកចាយព័ត៌មាន ផ្ទាល់ខ្លួននៅក្នុងបន្ទប់ជជែកកំសាន្តតាមបណ្តាញ អ៊ិនធឺណិត ឡើយ។
- មិនត្រូវចែករំលែករូបថតស៊ិចស៊ីរបស់អ្នកតាមបណ្តាញអ៊ិណធឺណិតឡើយ។
- ត្រូវចាំថា ព័ត៌មានលើបណ្តាញអ៊ិនធឺណិតមិនអាចលុបចេញបានឡើយ។

## ការបិទបញ្ចប់

ប្រាប់ឲ្យអ្នកចូលរួមសរសេរ ឬ សួរសំណួរ និង / ឬ ផ្តល់ជាព័ត៌មានត្រឡប់ និងប្រគល់ឲ្យទៅអ្នកសម្របសម្រួលដោយមិនបាច់បញ្ចេញឈ្មោះ។

អរគុណដល់អ្នកចូលរួមទាំងអស់គ្នាដែលបានមករៀន។ បញ្ជាក់ឡើងវិញអំពីការប្រជុំក្លឹបពេលក្រោយ។ ប្រាប់ពួកគេថា ពួកគេទទួលបានផ្កាយមួយទៀតសម្រាប់ការចូលរួមក្នុងម៉ោងសិក្សានេះ។

**ក ៖ ចោរ**

មនុស្សមិនអាចទាក់ទងអ្នកតាមរយៈអ៊ិនធឺណិតដើម្បីសុំឲ្យអ្នកផ្ញើប្រាក់ឲ្យគេ ឬ ដើម្បីលួចព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកដើម្បីអាចចូលបានទៅក្នុងគណនីធនាគារតាមអ៊ិនធឺណិត។ ល្បិចទូទៅគឺគេនិយាយថា អ្នកបានឈ្នះរង្វាន់ ឬអ្នកដែលផ្ញើនោះគឺជាមិត្តភក្តិរបស់អ្នកដែលកំពុងមានបញ្ហា។

**ខ ៖ ការការពារខ្លួនអ្នក**

មិនត្រូវឆ្លើយតបទៅអ៊ីម៉ែលណា ឬសារណាដែលអ្នកទទួល ពីមនុស្សមិនធ្លាប់ស្គាល់ទេ។ មិនត្រូវផ្ញើប្រាក់ ទៅកាន់ អ្នកដែលមិនធ្លាប់ស្គាល់ដែលទាក់ទងមកកាន់ អ្នកតាមអ៊ិនធឺណិតឡើយ។

**ក៖ អ្នកស៊ើបការ**

មនុស្ស អាចប្រើប្រាស់អ៊ិនធឺណិត ដើម្បីជួបគ្នា ដោយសង្ឃឹមថា ថ្ងៃណាមួយគេ នឹងរៀបចំជួបមុខផ្ទាល់។ នៅពេលជួបផ្ទាល់ គេអាចធ្វើទុក្ខទោស ដល់ជនរងគ្រោះ។ មនុស្សក៏អាចប្រើអ៊ិនធឺណិតដើម្បីឲ្យអ្នកប្រើផ្សេងទៀត ចែកចាយរូបថតរបស់គេផងដែរ ដែលអ្នកតាមដាន អាចចែកចាយជារូបថតអាសអាភាស។ មនុស្ស អាចប្រើប្រាស់ការផ្តល់នូវការងារ ក្លែងក្លាយ ដើម្បី ព្យាយាមបញ្ឆោតអ្នកឲ្យជួបគេ ឬឲ្យអ្នកធ្លាក់ក្នុងស្ថានភាពគ្រោះថ្នាក់ផងដែរ។

**ខ៖ ការការពារខ្លួនអ្នក**

មិនត្រូវទទួលយក “សំណើសុំធ្វើមិត្ត” (Friend Request) ពីមនុស្សមិនធ្លាប់ស្គាល់ឡើយ។ ជ្រើសរើសការកំណត់ ពាក្យសម្ងាត់កម្រិតខ្ពស់ (highest privacy) នៅលើបណ្តាញ ដូចជាហ្វេសប៊ុក។ (ឧ. កំណត់គណនីហ្វេសប៊ុករបស់អ្នក ដើម្បីឲ្យ “មិត្តរបស់អ្នកប៉ុណ្ណោះ” ដែលអាចមើលឃើញការបង្ហោះ ឬបន្ទាត់ពេលវេលា (Timeline) និងរូបថតរបស់អ្នក)។ មិនត្រូវជួបជាមួយអ្នកដែលអ្នកបានជួបនៅតាមបណ្តាញអ៊ិនធឺណិតឡើយ។ប្រសិនបើអ្នកជ្រើសរើសមិនអើពើដំបូន្មាននេះហើយ អ្នករៀបចំជួប ជាមួយគេត្រូវទៅជាមួយមិត្តភក្តិ និងជួបគេនៅពេលថ្ងៃនៅកន្លែងមានមនុស្សច្រើន។ ត្រូវមានការសង្ស័យលើការផ្តល់ ការងារតាមបណ្តាញអ៊ិនធឺណិត។ វាងាយស្រួលកុហក់ណាស់តាមអ៊ិនធឺណិត។

**ក៖ មនុស្សកម្រោល**

មនុស្សកម្រោល អាចប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិត ដើម្បីធ្វើទុក្ខទោសដល់អ្នកដទៃ។ គេអាចនិយាយរឿងឃោឃៅអំពីអ្នកដទៃ នៅលើទំព័រសាធារណៈដូចជា ហ្វេសប៊ុក ឬ គេអាចបង្ហាញពីរូបភាពពិតឬក្លែងក្លាយ (ប្រើកុំព្យូទ័រកែឲ្យមើលទៅដូចពិត) របស់អ្នកដទៃតាមប្រព័ន្ធអ៊ិនធឺណិត។ រូបទាំងនេះអាចធ្វើឲ្យមានភាពអាម៉ាស ឬធ្វើឲ្យឈឺចាប់ខ្លាំងណាស់។

**ខ៖ ការការពារខ្លួនអ្នក**

មិនត្រូវឲ្យគេដឹង ពីពាក្យសម្ងាត់ របស់អ្នក បើទោះបីជាមិត្តភក្តិ ឬមិត្តប្រុស/មិត្តស្រី។
មិត្តប្រុសរបស់អ្នក អាចថ្ងៃក្រោយក្លាយជាអតីតមិត្តប្រុសក៏ថាបាន។ គេអាចប្រើពាក្យសម្ងាត់របស់អ្នកដើម្បីចូលទៅក្នុងទំព័រហ្វេសប៊ុករបស់អ្នក ដោយបន្លំថា គេគឺជាអ្នក ហើយសរសេរអ្វីដែលអាចធ្វើឲ្យមានទុក្ខទោស ឬគួរឲ្យអាម៉ាស់។ ចូរចាំថា រូបភាពអ្វីមួយដែលអ្នកបង្ហោះពីខ្លួនអ្នកលើអ៊ិនធឺណិតគឺនៅលើអ៊ិនធឺណិតរហូត។ មិនអាចលុបចេញវិញបានទេ។ ដូច្នេះមិនត្រូវបង្ហោះរូបភាពអាម៉ាស់របស់អ្នកតាមអ៊ិនធឺណិតឲ្យនរណាម្នាក់ឲ្យសោះ។

## ក ៖ រូបភាពអាសអាភាស

YouTube និង Google អាចនាំអ្នកទៅកាន់វីដេអូ ឬវិបសាយដែលបង្ហាញពីរូបភាពអាសអាភាស ឬ មនុស្សដែលកំពុងរងការធ្វើទុក្ខទោស។ ទូរស័ព្ទក៏អាចប្រើដើម្បីផ្ញើវីដេអូ ឬសារបានដែលបង្ហាញពីមាតិកាផ្លូវភេទ។ វីដេអូទាំងនេះអាចបង្ហាញពីមនុស្សពិតដែលកំពុងត្រូវរងទុក្ខទោស ឬបន្ថោកតម្លៃ។ មនុស្សនៅក្នុងវីដេអូ អាចនឹងត្រូវបានគេបង្ខំឲ្យចូលរួម ដោយបុគ្គលផ្សេងទៀត ដែលត្រួតត្រាលើគេ ឬដោយសារភាពក្រីក្រខ្លាំងពេក។ ឬដោយសារ ត្រូវបានគេលួចថតស្ងាត់ដោយគ្មានការព្រមព្រៀង។ ប្រសិនបើអ្នកមើលវីដេអូអាសអាភាសអ្នកកំពុងគាំទ្រដល់ ឧស្សាហកម្មមួយដែលបន្ថោកតម្លៃ និងធ្វើទុក្ខទោសដល់មនុស្សហើយ។

## ខ: ការពារខ្លួនអ្នក

មិនត្រូវមើល វីដេអូអាសអាភាស តាមអ៊ីនធឺណិតទេ។ មិនត្រូវចែកចាយ មាតិកា បែបផ្លូវភេទ តាមទូរស័ព្ទកុំព្យូទ័ររបស់អ្នក ឬវិបសាយប្រព័ន្ធផ្សព្វផ្សាយសង្គមណាមួយឡើយ។ គិតឲ្យច្បាស់មុននឹងឲ្យនរណាម្នាក់យករូបថតរបស់អ្នក។ មិនត្រូវបញ្ចូលរូបថតរបស់អ្នក មិត្ត យុវជនរបស់អ្នកចូលទៅក្នុងការប្រកួតប្រជែងរូបថត តាមបណ្ដាញអ៊ីនធឺណិតឡើយ។ មិនត្រូវឲ្យនរណាម្នាក់យករូបថតសិចស៊ីរបស់អ្នកឡើយ។ អ្នកមិនដឹងពីគោលបំណងចុងក្រោយរបស់គេទេ។

## ក ៖ បណ្ដាញភ្ជាប់គួរសង្ស័យ

បណ្ដាញភ្ជាប់ (Link) គឺជាអាសយដ្ឋានអ៊ិនធឺណិត។ វាចាប់ផ្ដើមជាមួយនឹងwwwឬhttp។ នៅពេលដែលអ្នកចុចលើLinkមួយ វានឹងនាំអ្នកចូលទៅកាន់អាសយដ្ឋានមួយនៅលើអ៊ិនធឺណិត។ ឯកសារភ្ជាប់ (Attachment)៖ ឯកសារភ្ជាប់គឺជាឯកសារ ដែលអ្នកអាចទាញ យកទុកក្នុងកុំព្យូទ័ររបស់អ្នកបាន។ គណនីអ៊ីម៉ែល ភាគច្រើន ឯកសារភ្ជាប់ បង្ហាញជារូបឃ្នាប់ ខ្ទាស់ក្រដាស់នៅជាប់នឹងអ៊ីម៉ែល ហើយ ឯកសារដែល ភ្ជាប់មកនោះ ដែលមានចុងបញ្ចប់ ជាពាក្យថា “doc” “.docx” “.pdf” ឬ “.jpeg”។ Link និង Attachment អាចមាន គ្រោះ ថ្នាក់ ផងដែរ ពីព្រោះ វាអាចមានផ្ទុកមេរោគ។ មេរោគ គឺជា កម្មវិធី កុំព្យូទ័រមួយ ដែលគេបង្កើត ឡើង ដើម្បីបង្កបញ្ហា។ ពេល ខ្លះ មេរោគបំផ្លាញកម្មវិធី នៅក្នុងកុំព្យូទ័ររបស់អ្នក។ ពេលខ្លះវាអាចលួចព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកពីក្នុងកុំព្យូទ័ររបស់អ្នក។

## ខ ៖ការពារខ្លួនអ្នក

ប្រសិនបើ អ្នកទទួលបានអ៊ីម៉ែលពីមិត្តម្នាក់ ហើយគ្រាន់តែជា Attachment ឬ ជា Link មួយ (វាមិនមានការផ្ដាំផ្ញើ ឬការពន្យល់អ្វីពីមិត្តនោះ) នោះវាអាចជាមេរោគ។ ចូរកុំបើកវាឲ្យសោះ។

## ក ៖ ការលេងហ្គេមអិនធឺណិត

ពេលខ្លះមនុស្សប្រើអ៊ិនធឺណិតដើម្បីលេងហ្គេមកុំព្យូទ័រ។ ប្រសិនបើអ្នកជ្រើសធ្វើបែបនេះ ជាការសំខាន់ គឺត្រូវដឹងថាហ្គេមនេះអាចមានគ្រោះថ្នាក់។ មនុស្សចម្លែកអាចប្រើប្រាស់ហ្គេម ដើម្បីទាក់ទង យុវជនដើម្បីល្បួងគេឲ្យធ្លាក់ចូលក្នុងស្ថានភាពគ្រោះថ្នាក់។ មនុស្សក៏អាចញៀនទៅនឹង ហ្គេមកុំព្យូទ័រផងដែរ ហើយជាលទ្ធផលជីវិតទំនាក់ទំនង និងការងាររបស់គេអាចនឹងរងការប៉ះពាល់។ មាតិកាហ្គេមកុំព្យូទ័រ អាចបង្ហាញអ្វីដែលផ្ដល់ទុក្ខទោស ឬធ្វើឲ្យអន់តម្លៃដែលកើតមានចំពោះតួអង្គ។

## ខ: ការពារខ្លួនអ្នក

ប្រសិនបើអ្នក លេងហ្គេមកុំព្យូទ័រតាមអ៊ិនធឺណិត៖ មិនត្រូវជជែក ជាមួយមនុស្ស ដែលអ្នកមិនស្គាល់ឡើយ។ មិនត្រូវទទួលសំណើដើម្បីជជែកជាមួយ មនុស្សមិនធ្លាប់ស្គាល់ដែលទាក់ទងអ្នកតាមកម្មវិធីជជែកកំសាន្តឡើយ។ មិនត្រូវបង្ហាញពីព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកទៅកាន់មនុស្សដែលអ្នកមិនស្គាល់ឡើយ ដូចជា កន្លែងដែលអ្នករស់នៅសាលាដែលអ្នករៀន កន្លែងធ្វើការរបស់អ្នក ឬអាយុរបស់អ្នកឡើយ។ កំណត់ពេលដែល អ្នកចំណាយដើម្បីលេង។

# ១៨ IS ១៨ក ÷ រឿងរបស់មីង

មីង មានគណនីហ្វេសប៊ុកមួយ។ នាងបើកចំហាការកំណត់ពីសន្តិសុខ (Security Settings) របស់នាងទាំងអស់។ មានអ្នកជួញដូរមនុស្សម្នាក់ដែលធ្វើការនៅក្នុងទីក្រុងរបស់នាងបានប្រើប្រាស់ ហ្វេសប៊ុកដើម្បីជួញដូរក្មេងស្រីៗ។ ខាងក្រោមនេះគឺជាវិធីដែលបុគ្គលនោះបានធ្វើ។ បំបូងគេស្នើសុំធ្វើជា "មិត្ត" របស់នាងតាមហ្វេសប៊ុក។ មីង ទទួលយកអ្នកគ្រប់គ្នាដែលចង់ធ្វើជា "មិត្ត" របស់នាង ដូច្នេះនាងក៏ទទួលយកការស្នើរបស់គេនោះ។ បន្ទាប់មកបុរសនោះក៏ចាប់ផ្តើមសិក្សាពីទំព័រហ្វេសប៊ុករបស់នាង។ នៅក្នុងហ្វេសប៊ុកនោះ បុរសនោះរកបាននូវ ៖

- ទីតាំងរបស់នាង
- នាងចូលចិត្ត Taylor Swift
- ថ្ងៃ ខែ ឆ្នាំកំណើតរបស់នាង
- សាលារៀនរបស់នាង
- អាយុរបស់នាង
- ពីក្នុងរូបថតរបស់នាង គេរកឃើញថា នាងគឺជាក្មេងស្រីដែលស្រស់ស្អាតម្នាក់ ដែលនាងធ្លាប់ធ្លាប់មានកូនឆ្កែ ស មួយក្បាល ហើយនាងតែងតែទៅសួនក្នុងស្រុកមួយកន្លែង។

គេប្រើប្រាស់ព័ត៌មានទាំងនេះដើម្បីជួញដូរ មីង ដោយការផ្ញើសារទៅក្នុងគណនីហ្វេសប៊ុករបស់នាង។

ខាងក្រោមនេះគឺជាការសន្ទនារបស់គេ ៖

អ្នកជួញដូរ ៖ "អេ មីង ខ្ញុំមិនដឹងថា អ្នកចងចាំខ្ញុំដែរ ឬយ៉ាងណាទេ។ ខ្ញុំធ្លាប់រៀននៅសាលាបឋមសិក្សាជាមួយអ្នក ប៉ុន្តែខ្ញុំតែងតែអៀនខ្មាស់មិនហ៊ាននិយាយ ស្តី។ ខ្ញុំឈ្មោះ ចាន់។"

មីង ៖ "អូ សូស្តី ខ្ញុំមិនចាំអ្នកទេ សុំទោសផង"។

អ្នកជួញដូរ ៖ "មិនអីទេ ខ្ញុំចាំថា អ្នកចូលចិត្ត Taylor Swift។ តើអ្នកចូលចិត្តបទចម្រៀងថ្មីរបស់នាងដែរ ឬទេ?"

មីង ៖ "ខ្ញុំចូលចិត្តបទចម្រៀងនោះណាស់។ យើងចូលចិត្តតន្ត្រីប្រហែលគ្នាដែរ។"

អ្នកជួញដូរ ៖ " អ្នកស្អាតណាស់ ហើយសំឡេងរបស់អ្នកដូចាជា Taylor Swft អញ្ចឹង។"

មីង ៖ "តើអ្នកអាចផ្ញើរូបថតរបស់អ្នកឲ្យខ្ញុំមួយបានទេ?"
(គេផ្ញើរូបថតរបស់ក្មេងប្រុសស្អាតម្នាក់។)

អ្នកជួញដូរ ៖ "អេ មីង ពេលនេះជាថ្ងៃកំណើតរបស់អ្នក។ ខ្ញុំសូមជូនពរីករាយថ្ងៃកំណើត (គេផ្ញើរូបកូនឆ្កែមួយដែលដូចជាកូនឆ្កែពីមុនរបស់នាង)។តើអ្នកចូលចិត្តកូនឆ្កែថ្មីរបស់ខ្ញុំទេ?"

មីង ៖ "មានអារម្មណ៍ថា ផ្អែមល្ហែមដល់ហើយ។ ខ្ញុំចង់ឃើញកូនឆ្កែរបស់អ្នក។"

ការសន្ទនាមានលក្ខណៈបែបនេះជាច្រើនសប្តាហ៍ ។ ប្រុសម្នាក់នោះមើលកន្លែងដែលមីងទៅ តាម មុខងារប្រាប់ទីតាំងភូមិសាស្ត្រ និងរូបថតរបស់នាង។ ប្រុសម្នាក់នោះដឹងថា មីង រស់នៅក្នុង អន្តេវាសិកដ្ឋានមួយ ដែលមិនមានមិត្តភក្តិនៅក្នុងបន្ទប់ជាមួយនាងទេ ហើយគ្រួសាររបស់នាង រស់នៅឆ្ងាយពីនាង។ បុរសនោះដឹងថា នាងមិនពេញចិត្តនឹងការងាររបស់នាងទេ។ គេដឹងថា មីង មិនមានទូស័ព្ទដៃទេដើម្បីហៅគេឲ្យជួយនោះទេ។ មីងគិតថា គេជាមិត្តភក្តិរបស់នាង ហើយ នាងគិតថា នាងដូចជាស្រលាញ់គេខ្លះដែរ។ (ចាំថា រូបថតដែលគេផ្ញើឲ្យនាងគឺជារបស់អ្នក ផ្សេងទេ)។

អ្នកជួញដូរ ៖ "អេ មីង ទស្សន៍ទាយមើលថាមានអ្វី? បងប្អូនជីដូនមួយខ្ញុំបើកភោជនីយដ្ឋាន មួយនៅក្នុងទីក្រុងក្បែរនេះ។ គេត្រូវការអ្នករត់តុស្រីមួយចំនួន ហើយគេឲ្យប្រាក់ ខែច្រើនគួរសម។ ខ្ញុំគិតថា អ្នកគួរដាក់ពាក្យសាកមើល។"

មីង ៖ " ពិត ឬ ប៉ុន្តែខ្ញុំមិនដឹងធ្វើដូចម្តេចទេ"។

អ្នកជួញដូរ ៖ "កុំបារម្ភអី ខ្ញុំនឹងទៅធ្វើការនៅទីនោះដែរ។ ខ្ញុំអាចបង្ហាញប្រាប់អ្នកបាន ហើយបង ប្អូនជីដូនមួយខ្ញុំគឺជាមនុស្សល្អណាស់។ ខ្ញុំនឹងនាំអ្នកទៅជួបគេនៅថ្ងៃសម្រាក់របស់ អ្នក ប្រសិនបើអ្នកចង់។"

គេបានណាត់ជួបគ្នានៅសួនច្បារក្បែរនោះនៅថ្ងៃនាងឈប់សម្រាក់ពីការងារ។ នៅពេលមីង ទៅ ដល់ទីនោះ អ្នកជួញដូរនៅទីនោះ។ គេនិយាយថា មិត្តរបស់គេឈ្មោះ ចាន់ បានឈឺ ប៉ុន្តែ គេនឹង នាំនាងទៅកន្លែងធ្វើការនោះដើម្បីសម្ភាសន៍ជំនួសវិញ។ មីងបានទៅជាមួយបុរស ចំណាស់ នោះ ហើយនៅពេលនាងទៅដល់កន្លែងគោលដៅ នាងត្រូវ បានគេជួញដូរ។

នៅក្នុងក្រុមរបស់អ្នក ចូរគិតពីជំហាននានាដែល មីង គួរបានអនុវត្តដើម្បីឲ្យមានសុវត្ថិភាព។

# កំណត់ចំណាំ

សូមប្រើទំព័រនេះដើម្បីសរសេរកំណត់ចំណាំណាដែលអ្នកចង់ចងចាំនៅពេលដែលអ្នកត្រឡប់ទៅសហគមន៍របស់អ្នកវិញ។

........................................................................................................

........................................................................................................

........................................................................................................

........................................................................................................

........................................................................................................

........................................................................................................

........................................................................................................

........................................................................................................

........................................................................................................

........................................................................................................

........................................................................................................

........................................................................................................

........................................................................................................

........................................................................................................

........................................................................................................

........................................................................................................

........................................................................................................

........................................................................................................

........................................................................................................

........................................................................................................